# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការចុះបញ្ជីអចលនវត្ថុ
# ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

# និង

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី
# អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

រៀបចំដោយ
ក្រុមការងារអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និងសំណង់
និង
ក្រុមការងារប្រឹក្សាយោបល់របស់ប្រទេសជប៉ុន
ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ២០០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៣

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការចុះបញ្ជីអចលនវត្ថុ
# ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

# និង

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី
# អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី


រៀបចំដោយ
ក្រុមការងារអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និងសំណង់
និង
ក្រុមការងារប្រឹក្សាយោបល់របស់ប្រទេសជប៉ុន
ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌



ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ២០០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៣

ប្រកាសអន្តរក្រសួង ស្តីពីការចុះបញ្ជីអចលនវត្ថុ
ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
និង
ប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជី
អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ជំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៣

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

❖❖⚖❖❖

## ចំណាប់អារម្មណ៍របស់
## ឯកឧត្តម អង្គ វង្សវឌ្ឍានា
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ដែលបានចូលជាធរមាន និងកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបទប្បញ្ញត្តិមួយចំនួន តម្រូវឲ្យមានការចុះបញ្ជីអចលនវត្ថុ ដើម្បីអនុវត្តនូវសិទ្ធិ ដែលបានទទួលស្គាល់ដោយច្បាប់ ។

ដោយមើលឃើញនូវតម្រូវការចាំបាច់នេះ និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ កន្លងមកទោះបីជា ក្រសួងយុត្តិធម៌ មានភាពមមាញឹក ក្នុងការរៀបចំនូវបញ្ញត្តិគតិយុត្តនានាជាច្រើនក៏ដោយ ក៏ក្រសួងយុត្តិធម៌ សហការជាមួយអង្គការ JICA បានផ្តួចផ្តើម និងខិតខំប្រឹងប្រែងរៀបចំនូវបញ្ញត្តិគតិយុត្តដែលទាក់ទងទៅនឹងការចុះបញ្ជីអចលនវត្ថុនេះ ដើម្បីធានា និងអនុវត្តនូវបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ឲ្យមានប្រសិទ្ធិភាពខ្ពស់ ។

ជំហ៊ានតំបូង នៃការរៀបចំនូវបទប្បញ្ញត្តិគតិយុត្តដែលទាក់ទងទៅនឹង ការចុះបញ្ជីអចលនវត្ថុនេះ ក្រសួងយុត្តិធម៌ និងអង្គការ JICA បានធ្វើការស្រាវជ្រាវ ទៅលើបទប្បញ្ញត្តិនៃច្បាប់ជាតិ និងការអនុវត្តជាក់ស្តែងដែលបានអនុវត្តកន្លងមក ព្រមទាំងធ្វើការស្រាវជ្រាវ ទៅលើបទប្បញ្ញត្តិ និងការអនុវត្តន៍ល្អនៃបណ្តាប្រទេសនានាមួយចំនួន ក្នុងគោលដៅធានានូវប្រសិទ្ធិភាពនៃការចុះបញ្ជីអចលនវត្ថុ ឲ្យបានត្រឹមត្រូវទៅតាម ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី និងពង្រឹងកិច្ចការពារផលប្រយោជន៍ស្របច្បាប់ជូនប្រជាពលរដ្ឋ ។

ដើម្បីធ្វើឲ្យសម្រេចនូវការរៀបចំបទប្បញ្ញត្តិគតិយុត្តខាងលើនេះ ក្រុមការងារអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតឡើងតាមប្រកាសអន្តរក្រសួងលេខ ០៤ ប្រក.កយ.កដនស/០៨ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ហើយក្រុមការងារនេះ ក៏មានការចូលរួមសហការរៀបចំពីសំណាក់ជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ និងមានការប្រឹក្សាយោបល់ពីសាស្ត្រាចារ្យជប៉ុន ផងដែរ ។

នៅក្នុងការរៀបចំបទប្បញ្ញត្តិគតិយុត្តដ៏មានសារសំខាន់នេះ ក្រុមការងារអន្តរក្រសួង និងជំនាញការជប៉ុននៃអង្គការ JICA បានខិតខំប្រឹងប្រែងរួមគ្នា បំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ រហូតបានសម្រេចនូវសមិទ្ធិផលពីរ គួរឲ្យមោទនៈ គឺប្រកាសអន្តរក្រសួង

លេខ ៥៩ ប្រក.ដនស/១១ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ ស្ដីពី " ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី " និងប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ ស្ដីពី " នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី " ។

សមិទ្ធិផលទាំងពីរខាងលើនេះ រៀបចំបានយ៉ាងសមស្រប សម្រាប់អនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានលក្ខណៈទំនើបកម្ម នៃក្របខណ្ឌគតិយុត្ត ហើយក៏ជាសក្ខីភាពថ្មីបន្ថែមទៀត ដែលឆ្លុះបញ្ចាំងឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់របស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តតាមគោលនយោបាយ ស្ដីពី កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្ដេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ជំហ៊ានបន្ទាប់ ក្រុមការងារអន្តរក្រសួង និងអង្គការ JICA នឹងបន្តភារកិច្ចរបស់ខ្លួន ដើម្បីធ្វើការអប់រំ ផ្សព្វផ្សាយ នូវឧបករណ៍គតិយុត្តទាំងពីរខាងលើនេះ ឲ្យបានទូលំទូលាយ ដើម្បីលើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងមន្ត្រីអនុវត្តច្បាប់ នៅទូទាំងប្រទេស ។

ឆ្លៀតឱកាសនេះ ក្នុងនាមក្រសួងយុត្តិធម៌ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរដោយស្មោះអស់ពីចិត្ត ចំពោះការខិតខំប្រឹងប្រែងរបស់សមាជិក សមាជិការ នៃក្រុមការងារអន្តរក្រសួង ជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាស្ត្រាចារ្យជប៉ុន ដែលបានសហការរៀបចំនូវបទប្បញ្ញត្តិគតិយុត្តិដ៏មានសារៈសំខាន់នេះ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ការបោះពុម្ព ប្រកាសអន្តរក្រសួង ស្ដីពី " ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី " និងប្រកាសអន្តរក្រសួង ស្ដីពី " នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី " គឺជាការរួមចំណែក និងជាជំនួយដ៏សំខាន់ ក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងទាក់ទងទៅនឹងបញ្ញត្តិ " នៃការចុះបញ្ជីអចលនវត្ថុ " នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

## ប្រធានក្រុមការងារតាក់តែងច្បាប់

| | | |
|---|---|---|
| ឯកឧត្តម | **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |

## សមាសភាពចូលរួមពិគ្រោះយោបល់

| | | |
|---|---|---|
| ឯកឧត្តម | **ហ៊ី សោភា** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| លោក | Akio MORISHIMA | សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យ Nagoya |
| លោក | Ikufumi NIIMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Meiji |

## សមាសភាពក្រុមការងារអន្តរក្រសួង ទទួលបន្ទុកតាក់តែងប្រកាសអន្តរក្រសួង ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស)

| | | |
|---|---|---|
| លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ (**សហប្រធាន**) |
| ឯកឧត្តម | **លឹម វ៉ាន់** | សមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លីនៃក្រសួង ដ.ន.ស (**សហប្រធាន**) |
| ឯកឧត្តម | **យាន ស៊ីណា** | អតីតអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| ឯកឧត្តម | **សៀក វណ្ណា** | អនុរដ្ឋលេខាធិការនៃក្រសួងដ.ន.ស |
| ឯកឧត្តម | **ប៉ែន ពេជ្រសាលី** | អគ្គនាយកបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| ឯកឧត្តម | **ហ៊ុយ ផាប់** | សមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លីនៃក្រសួងដ.ន.ស |
| លោក | **ទិត ឫទ្ធី** | ចៅក្រមនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ម៉ៅ តិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **ស៊ូរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ |
| លោក | **សឹង បញ្ញាវុឌ្ឍ** | អតីតប្រធាននាយកដ្ឋានកិច្ចការអយ្យការនៃក្រសួងយុត្តិធម៌ |
| លោក | **ឈី លាង** | ប្រធាននាយកដ្ឋានអភិរក្សសុរិយោដីនៃក្រសួងដ.ន.ស |
| លោក | **ទូច ថារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ចេង ស្រ៊ុង** | ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាលនៃក្រសួងដ.ន.ស |
| លោក | **កុសល សុពិនត្ស** | ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងដ.ន.ស |
| លោក | **កែវ សេដ្ឋា** | អតីតអនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ប៉ាត់ សុភ** | អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដីនៃក្រសួងដ.ន.ស |
| លោក | **ឃិន មូ** | អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដីនៃក្រសួងដ.ន.ស |
| លោក | **សេង ពុទ្ធី** | អនុប្រធាននាយកដ្ឋានកិច្ចការនីតិកម្មនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **ប៉ិច ភានី** | អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដីនៃក្រសួងដ.ន.ស |
| លោក | **អ៊ឹង ចាន់ណា** | អតីតប្រធានការិយាល័យចុះបញ្ជីដីនៃក្រសួង ដ.ន.ស |
| លោក | **ឡុច សុខលៀង** | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការនៃក្រសួងយុត្តិធម៌ |
| លោក | **ស៊ុន ស៊ីរ** | អធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការនៃក្រសួងយុត្តិធម៌ |
| លោក | **ហុក ច័ន្ទសុវណ្ណារ៉ា** | អនុប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **អុល ធីរៈ** | អនុប្រធានការិយាល័យកិច្ចការអយ្យការនៃក្រសួងយុត្តិធម៌ |

| | | |
|---|---|---|
| កញ្ញា | **ឡាយ លីនណា** | អនុប្រធានការិយាល័យបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ស្ងួន ណារី** | មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងយុត្តិធម៌ |

## សមាសភាពក្រុមការងារប្រឹក្សាយោបល់របស់ប្រទេសជប៉ុន

| | | |
|---|---|---|
| លោក | Toshifumi MINAMI | ចៅក្រមសាលាឧទ្ធរណ៍នៃទីក្រុងតូក្យូ (ប្រធាន) |
| លោក | Michitaro URAKAWA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Tsuneo MATSUMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Hitotsubashi |
| លោក | Toyohiro NOMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushu-in |
| លោក | Minoru IINO | អតីតនាយកមជ្ឈមណ្ឌលសេវាព័ត៌មានចុះបញ្ជី នៃសមាគមន៍ច្បាប់រដ្ឋប្បវេណី |
| កញ្ញា | Tomoko SAWAMURA | មន្ត្រីការិយាល័យកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ |
| លោក | Takayuki KOKUBUN | មន្ត្រីការិយាល័យកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ |
| លោក | Takashi ITO | មន្ត្រីការិយាល័យកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ |
| កញ្ញា | Emiko NISHIMURA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌ |
| លោក | Kazuo UESAKA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌ |
| លោក | Sadao MATSUBARA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌ |
| លោក | Naoki ASAYAMA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌ |
| កញ្ញា | Miha ISOI | មេធាវី និងជាទីប្រឹក្សាជាន់ខ្ពស់របស់ JICA |

## សមាសភាពលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាយោបល់

| | | |
|---|---|---|
| លោក | Atsuhito YOSHIMOTO | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |
| លោក | Hisashi NAGAYA | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |

## ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌

| | | |
|---|---|---|
| លោក | Issei SAKANO | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Hiroshi KIYOHARA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Masayoshi HARADA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Emiko KANETAKE | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## អ្នកបកប្រែ :

| | | |
|---|---|---|
| លោក | **គីម ពេជ្រដា** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ម៉ាន្នី** | អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ឡៀប សុខសិរីយស** | ជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

## ជំពូកទី១- បទប្បញ្ញត្តិទូទៅ


ប្រការ ១ - គោលដៅ ....................................................................................... ២

ប្រការ ២ - គោលបំណង ................................................................................... ២

ប្រការ ៣ - វិសាលភាព .................................................................................... ២

ប្រការ ៤ - ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី .......................................................... ២


## ជំពូកទី២- ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី

### ផ្នែកទី ១- ទម្រង់ និងឯកសារភ្ជាប់ នៃលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី


ប្រការ ៥ - ទម្រង់នៃលិខិតផ្ទុកផ្តាក់ ..................................................................... ៣

ប្រការ ៦ - ឯកសារភ្ជាប់ជាមួយលិខិតផ្ទុកផ្តាក់ ........................................................ ៣


### ផ្នែកទី ២- ប្រភេទនៃលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី

#### កថាភាគទី ១- ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ


ប្រការ ៧ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយផ្អែកលើមាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ..................................... ៤

ប្រការ ៨ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ....................................................................... ៥

ប្រការ ៩ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការផ្ទេរផលុបភោគ តាមការលក់ដោយបង្ខំ ដោយផ្អែកលើមាត្រា ៤៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ...... ៧


#### កថាភាគទី ២- ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ


ប្រការ ១០ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៥១១ និងមាត្រា ៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី .... ៨

ប្រការ ១១ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ......................................... ១០

ប្រការ ១២ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ......... ១១


#### កថាភាគទី ៣- ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត


ប្រការ ១៣ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូស ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី............................................................................ ១៣

ប្រការ ១៤ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដោយផ្អែកលើមាត្រា ៤០៨ មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ១៥
ប្រការ ១៥ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ១៧

**កថាភាគទី ៤- ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

ប្រការ ១៦ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកលើកថាខណ្ឌទី ៣ និងទី៤ នៃមាត្រា ៥៦៧ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ១៩
ប្រការ ១៧ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកលើកថា-ខណ្ឌទី៣ និងទី៤ នៃមាត្រា ៥៦៧ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ២០

**កថាភាគទី៥- ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត**

ប្រការ ១៨ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើមាត្រា ៥៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ២៤
ប្រការ ១៩ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី៥ នៃមាត្រា ៥៦៦ មាត្រា ៤០៨ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ២៥

**កថាភាគទី ៦- ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន**

ប្រការ ២០ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុដោយផ្អែកលើមាត្រា ៥៧០ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ៣០
ប្រការ ២១ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងដោយផ្អែកលើមាត្រា ៥៧០ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ........ ៣១

**ផ្នែកទី ៣- នីតិវិធីនៃការចុះបញ្ជី**

**កថាភាគទី ១- បទប្បញ្ញត្តិទូទៅ**

ប្រការ ២២ - នីតិវិធីនៃការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៣៥

**កថាភាគទី ២- របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**

ប្រការ ២៣ - របៀបចុះបញ្ជីអំពីការរឹបអូសក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៣៥
ប្រការ ២៤ - របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៣៧
ប្រការ ២៥ - របៀបចុះបញ្ជីអំពីការផ្ទេរសិទ្ធិ អំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ អំពីការលុប

ការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ន អំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ........ ៣៨

**កថាភាគទី ៣- របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ**

ប្រការ ២៦ - របៀបចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ .៤៥

ប្រការ ២៧ - របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៤៦

ប្រការ ២៨ - របៀបចុះបញ្ជីអំពីការផ្ទេរសិទ្ធិ អំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ អំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ន អំពីការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន តាមការអនុវត្តសិទ្ធិប្រាតិភោគ ........ ៤៧

**កថាភាគទី ៤- របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត**

ប្រការ ២៩ - របៀបចុះបញ្ជីអំពីការរឹបអូសចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៥៤

ប្រការ ៣០ - របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៥៦

ប្រការ ៣១ - របៀបចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៥៨

**កថាភាគទី ៥- របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

ប្រការ ៣២ - របៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៦០

ប្រការ ៣៣ - របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៦២

**កថាភាគទី ៦- របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត**

ប្រការ ៣៤ - របៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៦៣

ប្រការ ៣៥ - របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ... ៦៥

**កថាភាគទី ៧- របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន**
ប្រការ ៣៦ - របៀបចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៦៧
ប្រការ ៣៧ - របៀបចុះបញ្ជីអំពីការលុបការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ ........ ៦៩

**កថាភាគទី ៨- នីតិវិធីបន្ទាប់ពីការចុះបញ្ជី**
ប្រការ ៣៨ - ការផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ទៅក្រឡាបញ្ជី ........ ៧១
ប្រការ ៣៩ - លិខិតផ្ទុកផ្តាក់ឲ្យកែតម្រូវ ........ ៧១

**ជំពូកទី៣- ការចុះបញ្ជីតាមអំណាចសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ**
ប្រការ ៤០ - ការចុះបញ្ជីតាមសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្ត ដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ ........ ៧២

**ជំពូកទី៤- អន្តរប្បញ្ញត្តិ**
ប្រការ ៤១ - វិធានការអន្តរកាលទូទៅ ........ ៧២
ប្រការ ៤២ - វិធានការអន្តរកាលស្តីពីសិទ្ធិជួលរយៈពេលវែង ........ ៧២

**ជំពូកទី៥- អវសានប្បញ្ញត្តិ**
ប្រការ ៤៣ - កាលបរិច្ឆេទនៃការអនុវត្ត ........ ៧៣
ប្រការ ៤៤ - និរាករណ៍ នៃបទប្បញ្ញត្តិដែលផ្ទុយ ........ ៧៣
ឧបសម្ព័ន្ធទី ១ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ........ ៧៤
ឧបសម្ព័ន្ធទី ២ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ........ ៧៦
ឧបសម្ព័ន្ធទី ៣ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ........ ៧៨
ឧបសម្ព័ន្ធទី ៤ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ.... ៨១
ឧបសម្ព័ន្ធទី ៥ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ........ ៨៣
ឧបសម្ព័ន្ធទី ៦ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគតាមការអនុវត្តសិទ្ធិប្រាតិភោគ ........ ៨៥
ឧបសម្ព័ន្ធទី ៧ - ពាក្យសុំធ្វើការផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ........ ៨៨
ឧបសម្ព័ន្ធទី ៨ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ........ ៩០

ឧបសម្ព័ន្ធទី ៩ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត........ ៩២
ឧបសម្ព័ន្ធទី ១០ - ពាក្យសុំផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត........ ៩៤
ឧបសម្ព័ន្ធទី ១១ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត........ ៩៦
ឧបសម្ព័ន្ធទី ១២ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន........ ៩៨
ឧបសម្ព័ន្ធទី ១៣ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន........ ១០០
ឧបសម្ព័ន្ធទី ១៤ - ពាក្យសុំផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត........ ១០២
ឧបសម្ព័ន្ធទី ១៥ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត........ ១០៤
ឧបសម្ព័ន្ធទី ១៦ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត........ ១០៦
ឧបសម្ព័ន្ធទី ១៧ - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ........ ១០៨
ឧបសម្ព័ន្ធទី ១៨ - លិខិតផ្ទុកផ្តាក់ឲ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ........ ១១០

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការចុះបញ្ជីអចលនវត្ថុ

# ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ក្រសួងយុត្តិធម៌**

លេខ :.៤៥.ប្រក.ដ.ន.ស/១១

រាជធានីភ្នំពេញ, ថ្ងៃទី.០៣.ខែ.វិច្ឆិកា..ឆ្នាំ ២០១១

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៦អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- តាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី



ℎ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីអចលនវត្ថុឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

១-ប្រកាសនេះ បញ្ញត្តអំពីនីតិវិធីនៃការផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស ការផ្ទេរ ការលុបចោល ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីនៃការចុះបញ្ជីទាំងនោះ ។

២-ប្រកាសនេះ ក៏បញ្ញត្តផងដែរអំពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុតាមរយៈ សាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ យោងតាមមាត្រា ៥២៩ (ការចាត់ទុកថាបានបង្ហាញឆន្ទៈ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ ត្រូវយកមកអនុវត្ត ចំពោះដីដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយដែលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានចេញ ។

ប្រកាសនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលត្រូវបានចុះបញ្ជី ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ។

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី**

ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីតាមន័យនៃប្រកាសនេះ គឺរដ្ឋបាលសុរិយោដីដែលបានកំណត់ដូចខាងក្រោមនេះ :

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ នៃប្រការ ២ (គោលបំណង)

ក្រឡាបញ្ជីត្រូវផ្ញើលិខិតផ្ទុកផ្តាក់ទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ២ នៃប្រការ ២ (គោលបំណង) ភាគីឈ្នះក្តី ឬ ភាគីដែលមានកំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់នូវការទាមទារត្រូវដាក់ពាក្យសុំទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុដែលត្រូវចុះបញ្ជីតាំងនៅ ឬ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។

## ជំពូកទី ២

## ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី

### ផ្នែកទី ១

### ទម្រង់ និងឯកសារភ្ជាប់ នៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

**ប្រការ ៥ : ទម្រង់នៃលិខិតផ្ទុកផ្តាក់**

លិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី ។ ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់ ដូចមានចែងក្នុងផ្នែកទី ២ (ប្រភេទនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី) នៃជំពូកទី ២ (ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី) នៃប្រកាសនេះ ដោយមានបង្ហាញនៅក្នុងគំរូឧបសម្ព័ន្ធទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់នីមួយៗ ។

**ប្រការ ៦ : ឯកសារភ្ជាប់ជាមួយលិខិតផ្ទុកផ្តាក់**

នៅពេលប្រគល់លិខិតផ្ទុកផ្តាក់ ក្រឡាបញ្ជីត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់ ដូចមានចែងក្នុងផ្នែកទី ២ (ប្រភេទនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី) នៃជំពូកទី ២ (ការចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី) នៃប្រកាសនេះ ។

## ផ្នែកទី ២

## ប្រភេទនៃលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី

### កថាភាគទី ១

### ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ប្រការ ៧** : លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយផ្អែកលើមាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការអនុវត្ត ចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ។

បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ត្រូវបានចេញរួចហើយ តែមានពាក្យសុំអនុវត្តដោយបង្ខំថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការបានទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំថ្មីមួយទៀត (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ។

ចំពោះការចុះបញ្ជីដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ៧ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ) នេះ លិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :......................(សរសេរអំពីខ្លឹមសារនៃការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..........................................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន......................)

គ-គោលបំណងនៃការចុះបញ្ជី..........................................(រឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច "ក")

ឃ-មូលហេតុ..............................(ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ

លេខ.......ចុះថ្ងៃទី......ខែ.....ឆ្នាំ......និងឈ្មោះរបស់តុលាការ...........................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត......................(អាសយដ្ឋាន.............. ..............................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន.............. ..............................)

ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូត នៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំផង ដែរ ។

**ប្រការ ៨ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំបានកើតឡើងទៅលើអចលនវត្ថុដែលត្រូវរឹបអូស ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ហើយលិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:......................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ...........................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន.....................................................)

គ-គោលបំណងនៃការចុះបញ្ជី................. (លុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច “ក” )

ឃ-មូលហេតុ...................(ពាក្យសុំលក់ដោយបង្ខំត្រូវបានដកចេញ ចុះថ្ងៃទី..... ខែ........ឆ្នាំ......... ឬដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី...... ខែ.......ឆ្នាំ........ ហើយថ្ងៃទី....ខែ........ឆ្នាំ......... ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ.............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន............ ..............................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន............
.............................) ។

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីមានការដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ :

ក-នៅពេលដែលការដាក់ពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដាក់ពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដាក់ពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំមានអានុភាព :

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជី ថាបានចូលជាស្ថាពរ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ឃ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ង-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ៤ នៃមាត្រា ៤៤៣ (វិធានការក្នុងករណីលក់ហួសកម្រិត) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

**ប្រការ ៩ :** **លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការផ្ទេរផលុបភោគ តាមការលក់ដោយបង្ខំ ដោយផ្អែកលើមាត្រា ៨៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគដែលអ្នកទិញបានធ្វើលទ្ធកម្ម និងឱ្យលុបការចុះបញ្ជីដោយត្រូវ :

១-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

២-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៣-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ។

៤-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ។

ចំពោះលិខិតផ្ទុកផ្ដាក់នៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :.....................................(សរសេរអំពីខ្លឹមសារនៃការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី )

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ....... (អាសយដ្ឋាន .....................................)

គ-គោលបំណងនៃការចុះបញ្ជី :

-ផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការលក់ដោយបង្ខំទៅអោយឈ្មោះ.......................

-លុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ទៅលើចំណុច “ក”

-លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច “ក”

-លុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ទៅលើចំណុច“ក” ។

ឃ-មូលហេតុ :

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........ចុះថ្ងៃទី.....ខែ......ឆ្នាំ......និងឈ្មោះរបស់តុលាការ...................................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...............នៅថ្ងៃទី.....ខែ.....ឆ្នាំ.....។

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន............................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន............................................)

ឆ-អត្តសញ្ញាណអ្នកទិញ.................(ថ្ងៃទី......ខែ.......ឆ្នាំ.......ទីកន្លែងកំណើត ឈ្មោះឪពុកម្ដាយ អាសយដ្ឋាន............................ របស់អ្នកទិញ) ។

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ២
## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**ប្រការ ១០ :** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៥១១ និងមាត្រា ៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការអនុវត្តចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមាន

សមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគនោះ ។

បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញរួចហើយ តែមានពាក្យសុំអនុវត្តសិទ្ធិប្រាតិភោគថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការបានទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីមួយទៀត (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ច ធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយអនុវត្តសិទ្ធិប្រាតិភោគ ។

ចំពោះការចុះបញ្ជីដូចមានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការ ១០ (លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ) នេះ លិខិតផ្ទុកផ្តាក់ក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) ត្រូវសរសេរបន្ថែម នូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ: ........................(សរសេរអំពីខ្លឹមសារការផ្ទុកផ្តាក់ចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..........................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី )

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ......... (អាសយដ្ឋាន ..............................................)

គ-គោលបំណងនៃការចុះបញ្ជី...........................(រឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុ ចំណុច "ក" )

ឃ-មូលហេតុ.....................(ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.......និងឈ្មោះរបស់តុលាការ............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត......................(អាសយដ្ឋាន............... ...............................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន............. ...............................)

ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូត នៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំផងដែរ ។

**ប្រការ ១១ : លិខិតផ្អាកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៨២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើងទៅលើការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ក្រឡាបញ្ជីត្រូវផ្អាកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ហើយលិខិតផ្អាកផ្តាក់ទៅក្នុងវាក្យខណ្ឌទី ២ នៃប្រការ ៥ (ទម្រង់នៃលិខិតផ្អាកផ្តាក់) ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:.....................(សរសេរអំពីខ្លឹមសារផ្អាកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ .......(អាសយដ្ឋាន............................................)

គ-គោលបំណងនៃការចុះបញ្ជី..........................(លុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគលើអចលនវត្ថុចំណុច “ក” )

ឃ-មូលហេតុ...............(ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវបានដកចេញ ចុះថ្ងៃទី......ខែ.........ឆ្នាំ......... ឬ ដីកាសម្រេចឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ........ឆ្នាំ........... ហើយថ្ងៃទី......ខែ........ឆ្នាំ........ ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ..............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន............... ..........................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន................ ..........................................)

ឯកសារភ្ជាប់ជាមួយ:

១-ក្នុងករណីមានការដកពាក្យសុំការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹម

ត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំ ធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ មានអានុភាព :

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៤៩៨ (ការផ្អាក និងការលុបចោលការអនុវត្តសិទ្ធិប្រាតិភោគ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥(ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវលិខិតចម្លងយថាភូតនៃដីកាសម្រេចលុបចោល ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធី ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

ឃ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៤៣៥ (វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់)ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ។

ង-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ៤ នៃមាត្រា ៤៤៣ (វិធានការក្នុងករណីលក់ហួសកម្រិត) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

**ប្រការ ១២ : លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគតាមការអនុវត្តសិទ្ធិប្រាតិភោគដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម និងឱ្យលុបការចុះបញ្ជី ។ ប៉ុន្តែក្នុងករណីអ្នកទិញជាអ្នកធានាដោយវត្ថុ ដែលជាម្ចាស់សិទ្ធិដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ក្រឡាបញ្ជីមិនចាំបាច់ធ្វើការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគទេ ។

ចំណុចដែលត្រូវផ្ទុកផ្ដាក់ឱ្យចុះបញ្ជីផ្ទេរសិទ្ធិ និងឱ្យលុបការចុះបញ្ជីគឺ :

១-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

២-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

៣-ផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ។

៤-ផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ :....................(សរសេរអំពីខ្លឹមសារនៃការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ដែលអ្នកទិញបានធ្វើលទ្ធកម្ម ឱ្យលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន )

ក-អត្តសញ្ញាណនៃអចលនវត្ថុ...........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ (អាសយដ្ឋាន................................................)

គ-គោលបំណងនៃការចុះបញ្ជី :

-ផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ តាមការលក់ដោយបង្ខំទៅឱ្យឈ្មោះ ..................................

-លុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច “ក”

-លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់ ទៅលើចំណុច “ក”

-លុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ទៅលើចំណុច “ក” ។

ឃ-មូលហេតុ ៖

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......ចុះថ្ងៃទី....ខែ.....ឆ្នាំ..... និងឈ្មោះរបស់តុលាការ.........................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ..................នៅថ្ងៃទី........ខែ.......ឆ្នាំ.........

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត..................(អាសយដ្ឋាន................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត......................(អាសយដ្ឋាន................)

ឆ-អត្តសញ្ញាណអ្នកទិញ..............................(ថ្ងៃទី.....ខែ.....ឆ្នាំ......ទីកន្លែងកំណើត ឈ្មោះឪពុកម្ដាយ អាសយដ្ឋាន ...........................................)

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូត នៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ដែលបញ្ជាក់ថាអ្នកទិញ បានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ៣
## ការចុះបញ្ជីដែលពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំចំពោះ សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ១៣ ៖ លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានចុះបញ្ជីបានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។

ចំពោះពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុល (ប្រសិនបើមាន)

-សញ្ញាណរបស់ម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុលនៃការអនុវត្ត និងកូនបំណុលទី ៣

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃសិទ្ធិលើបំណុល ដែលម្ចាស់បំណុលទាមទារឱ្យអនុវត្តដោយបង្ខំទៅលើកូនបំណុលនៃការអនុវត្ត ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:..............................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ...... ..............................(អាសយដ្ឋាន..................................................)

គ-គោលបំណងនៃការចុះបញ្ជី...........................(ការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ....................(ដីកាសម្រេចរឹបអូសលេខ.....ចុះថ្ងៃទី.....ខែ..... ឆ្នាំ.....ហើយថ្ងៃទី.....ខែ.....ឆ្នាំ......ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ ..................................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន........... .......................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.............................(អាសយដ្ឋាន......... .......................)

ឆ-ឈ្មោះកូនបំណុលទី ៣ ............................(អាសយដ្ឋាន.................
.......................)

ជ- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូស ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជី អំពីកាលបរិច្ឆេទ ដែលដីកាសម្រេចរឹបអូសនោះមានអានុភាព។

ចំពោះដីកាសម្រេចរឹបអូសខាងលើមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលមានសេចក្តីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

**ប្រការ ១៤ : លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដោយផ្អែកលើមាត្រា ៤០៨ មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើមានពាក្យសុំឱ្យលុបការចុះបញ្ជី ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ក្នុងករណីណាមួយដូចខាងក្រោមនេះ :

- បើពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលត្រូវបានដកវិញ ឬ
- បើដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលមានអានុភាព ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការផ្ញើប្រាក់ទៅតុលាការអនុវត្តដូចជា : សញ្ញាណនៃរឿងក្ដី ឈ្មោះនាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត មូលហេតុនៃការផ្ញើចំនួនទឹកប្រាក់ដែលបានផ្ញើជាដើម ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:...........................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណ

ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលធានាសិទ្ធិលើបំណុលដែលត្រូវបាន
រឹបអូស)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.........
(អាសយដ្ឋាន ..................................................................................)

គ-គោលបំណងនៃការចុះបញ្ជី.................(ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិ
លើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុ
ចំណុច "ក")

ឃ-មូលហេតុ........................(ការដកពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល
នៅថ្ងៃទី.......ខែ......ឆ្នាំ.......ដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុល
លេខ......ចុះថ្ងៃទី......ខែ.......ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ......ដែលមានអានុភាព
និងឈ្មោះរបស់តុលាការ ឬ ការសងប្រាក់ ឬ ការធ្វើប្រាក់របស់កូនបំណុលទី ៣ ចុះថ្ងៃទី.....
ខែ......ឆ្នាំ........)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត........................(អាសយដ្ឋាន...........
...........................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត............................(អាសយដ្ឋាន..........
...........................................)

ឆ-ឈ្មោះកូនបំណុលទី៣.................................(អាសយដ្ឋាន..........
...........................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល ដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីមានការដកពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុល :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លង យថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានអានុភាព :



ƒ ✗

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ)

ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

៣-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុល នៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តនោះ ។

៤-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការអនុវត្ត :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីកូនបំណុលទី ៣ ។

## ប្រការ ១៥ : លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើបានបញ្ចប់ការលក់ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតរួចហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជី

ផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូសតាមពាក្យសុំរបស់អ្នកទិញ ។

ចំពោះពាក្យសុំរបស់អ្នកទិញ ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលត្រូវបានផ្ទេរ

-សញ្ញាណអ្នកទិញ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណម្ចាស់អចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

-មូលហេតុនៃការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:..................................(សរសេរអំពីខ្លឹមសារឱ្យចុះបញ្ជីផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូស)

ក-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (អាសយដ្ឋាន.........................)

គ-គោលបំណងនៃការចុះបញ្ជី.......................(ផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត និងលុបការចុះបញ្ជីអំពីការរឹបអូស )

ឃ-មូលហេតុ.................(អាជ្ញាសាលាបានទទួលប្រាក់ពីការលក់ នៅថ្ងៃទី....... ខែ........ឆ្នាំ........... និងឈ្មោះរបស់តុលាការ.........................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត......................(អាសយដ្ឋាន.............. .....................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត........................(អាសយដ្ឋាន.............. .....................................)

ឆ-ឈ្មោះកូនបំណុលទី ៣..................................(អាសយដ្ឋាន............ .....................................)

ជ-អត្តសញ្ញាណអ្នកទិញ..................................(អាសយដ្ឋាន............
......................................)

ឈ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់

-ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម នៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅអាជ្ញាសាលារួចហើយ

-ឯកសារចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកទិញ ។

## កថាភាគទី ៤

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**ប្រការ ១៦ : លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នដោយផ្អែកលើកថាខណ្ឌទី៣ និងទី ៤ នៃមាត្រា ៥៦៧ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

នៅពេលដែលតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល ។

បើដីកាសម្រេចការរឹបអូសជាបណ្ដោះអាសន្នបានអនុវត្តរួចហើយ តែមានពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នថ្មីទៀត (ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល (ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចចេញដោយតុលាការផ្សេង យោងតាមមាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:............................(សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន...............................)

ក-អត្តសញ្ញាណនៃអចលនវត្ថុ...........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ................. (អាសយដ្ឋាន ..................................)

គ-គោលបំណងនៃការចុះបញ្ជី................(ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ទៅលើអចលនវត្ថុចំណុច"ក")

ឃ-មូលហេតុ...................................(ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ.......ចុះថ្ងៃទី..... ខែ.....ឆ្នាំ.......និងឈ្មោះរបស់តុលាការ....................... ។

ង-ឈ្មោះម្ចាស់បំណុល...............................(អាសយដ្ឋាន.................................................................)

ច-ឈ្មោះកូនបំណុល..................................(អាសយដ្ឋាន.................................................................)

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។

**ប្រការ ១៧ : លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកលើកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៥៦៧ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ បើពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានដក ឬ បើដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្នបានបង្កើតអានុភាព ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ច ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:....................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន................................)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ...... .....................(អាសយដ្ឋាន .....................................................)

គ-គោលបំណងនៃការចុះបញ្ជី (ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគទៅលើអចលនវត្ថុ ចំណុច "ក")

ឃ-មូលហេតុ.........................(ការដកពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្ន ឬ ការដកពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី.....ខែ.......ឆ្នាំ........ ឬដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នលេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ.......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ.....................)

ង-ឈ្មោះម្ចាស់បំណុល....................................(អាសយដ្ឋាន............... ...........................................................)

ច-ឈ្មោះកូនបំណុល....................................(អាសយដ្ឋាន............... ...........................................................)

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូត នៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

៣-ក្នុងករណីការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានលុបចោល :

ក-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៩ (ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ខ-ក្នុងករណីដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានលុបចោលផ្អែកលើមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព) និងមាត្រា ៥៦១ (បណ្ដឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី ៦) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ក” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងចំណុច “ឆ” កថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ឃ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ង” (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជា ដែលមានខ្លឹមសារថា មិនអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ឬ ក៏ដកពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬដកពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ង-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការ

សម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច“ឆ” “ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន យោងតាមកថាខណ្ឌ ទី ២ នៃមាត្រា ៣៦៧ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរតាមមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) ឬ អនុសារសាលក្រមចុងក្រោយ នៃបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តដែលបង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ច-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី ៦) មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” “ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន យោងកថាខណ្ឌទី ២ នៃមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ា ចំពោះការទាមទារជា អាទិ៍) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរតាម មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) ឬអនុសារសាលក្រមចុងក្រោយនៃបណ្ដឹងតវ៉ារបស់តតិយជន ដែលបង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ឆ-ការលុបចោលដោយផ្អែកលើថាខណ្ឌទី៤ នៃមាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

ជ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ។

## កថាភាគទី ៥

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ១៨ :** លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើមាត្រា ៥៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើតុលាការបានចេញដីកាសម្រេចហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុលចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសជាបណ្តោះអាសន្ន តាមពាក្យសុំរបស់ម្ចាស់បំណុល ។

ចំពោះពាក្យសុំរបស់ម្ចាស់បំណុលដូចមានចែងក្នុងកថាខណ្ឌទី ១ នេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុល (ប្រសិនបើមាន)

-សញ្ញាណរបស់ម្ចាស់បំណុលកម្មសិទ្ធិករនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុល និងកូនបំណុលទី ៣

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃសិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:............................ (សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ........ .................. (អាសយដ្ឋាន..................................................................)

គ-គោលបំណងនៃការចុះបញ្ជី.......................(ការរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ....................(ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលលេខ......ថ្ងៃទី.....ខែ.....ឆ្នាំ......ហើយថ្ងៃទី.....ខែ.......ឆ្នាំ.......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ..........................................)

ង-ឈ្មោះម្ចាស់បំណុល.......................................(អាសយដ្ឋាន............................................................)

ច-ឈ្មោះកូនបំណុល.......................................(អាសយដ្ឋាន............................................................)

ឆ-ឈ្មោះកូនបំណុលទី៣................................(អាសយដ្ឋាន............................................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីអំពីកាលបរិច្ឆេទ ដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះមានអានុភាព ។

ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នខាងលើ មានអានុភាពនៅពេលដែលបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុលដែលមានសេចក្តីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

**ប្រការ ១៩ : លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី ៥ នៃមាត្រា ៥៦៦ មាត្រា ៤០៨ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើមានពាក្យសុំឱ្យលុបការចុះបញ្ជី ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគ

ផ្សេងទៀត ក្នុងករណីណាមួយដូចខាងក្រោមនេះ :

-បើពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតត្រូវបានដក ឬ

-បើពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ត្រូវបានដក ឬ

-បើដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត បានបង្កើតអានុភាព ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:......................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ............................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ........ .................. (អាសយដ្ឋាន....................................................)

គ-គោលបំណងនៃការចុះបញ្ជី........................(លុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុ ចំណុច“ក”)

ឃ-មូលហេតុ.............. (ការដកពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ឬ ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតនៅថ្ងៃទី......ខែ......ឆ្នាំ....... ឬដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតលេខ.....ចុះថ្ងៃទី......ខែ.....ឆ្នាំ.....ដែលមានអានុភាពនៅថ្ងៃទី.....ខែ....ឆ្នាំ...... និងឈ្មោះរបស់តុលាការ.........................)

ង-ឈ្មោះម្ចាស់បំណុល............................(អាសយដ្ឋាន....................
...............................................)

ច-ឈ្មោះកូនបំណុល.............................(អាសយដ្ឋាន....................
...............................................)

ឆ-ឈ្មោះកូនបំណុលទី ៣........................(អាសយដ្ឋាន......................
...............................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

៣-ក្នុងករណីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានលុបចោល :

ក-ការលុបចោលដោយសារការធ្វើប្រាក់រំដោះអំពីការរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើមាត្រា ៥៦៩ (ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) “ រួមទាំងករណីដែលការធ្វើប្រាក់ដែលស្មើនឹងចំនួនប្រាក់ នៃសិទ្ធិលើបំណុលដោយកូនបំណុលទី ៣ ត្រូវចាត់ទុកថាជាការធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ដោយយោងតាមកថាខណ្ឌទី ៣ នៃមាត្រា ៥៦៦ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លង

យថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការវិបអូសជាបណ្ដោះអាសន្ន ។

ខ-ក្នុងករណីដីកាសម្រេចវិបអូសជាបណ្ដោះអាសន្នត្រូវបានលុបចោល ដោយផ្អែកលើមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្ដូរស្ថានភាព) និងមាត្រា ៥៦១ (បណ្ដឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការវិបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោល ការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ក" ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការវិបអូសជាបណ្ដោះអាសន្ន ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ង" ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការវិបអូសជាបណ្ដោះអាសន្ន ។

ឃ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ង" (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជាដែលមានខ្លឹមសារថា មិនអនុវត្តការវិបអូសជាបណ្ដោះអាសន្ន ឬ ក៏ដកពាក្យសុំដីកាសម្រេចវិបអូសជាបណ្ដោះអាសន្ន ឬ ដកពាក្យសុំអនុវត្តការវិបអូសជាបណ្ដោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការវិបអូសជាបណ្ដោះអាសន្ន ។

ង-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និង មាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ង" (ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការវិបអូសជាបណ្ដោះអាសន្ន យោង

តាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រម ចុងក្រោយនៃបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តដែល បង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូស ជាបណ្តោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

ច-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និង មាត្រា ៣៧០ (ការផ្អាកនិងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” (ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្ត ការរឹបអូសជាបណ្តោះអាសន្ន យោងតាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រមចុងក្រោយ នៃបណ្តឹងតវ៉ារបស់តតិយជន ដែលបង្គាប់ឱ្យលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

ឆ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៤ នៃមាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

ជ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា ៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ។

## កថាភាគទី ៦
## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

**ប្រការ ២០:** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុដោយផ្អែកលើមាត្រា ៥៧០ មាត្រា ៥២០ មាត្រា ៥២៤ និងមាត្រា ៥២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅពេលដែលតុលាការបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងតាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល ។

បើដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុបានអនុវត្តរួចហើយ តែមានពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុដដែលថ្មីមួយទៀត ហើយតុលាការទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការត្រូវចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នថ្មីមួយទៀត (ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ច ធ្វើការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ តាមពាក្យសុំឱ្យអនុវត្តរបស់ម្ចាស់បំណុល ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:...........................(គឺសរសេរអំពីខ្លឹមសារការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ.................... (អាសយដ្ឋាន ..........................................)

គ-គោលបំណងនៃការចុះបញ្ជី.....................(ការចាត់ចែងជាបណ្ដោះអាសន្ន ចំណុច “ក” )

ឃ-មូលហេតុ....................(ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ..... ចុះថ្ងៃទី.....ខែ......ឆ្នាំ......និងឈ្មោះរបស់តុលាការ.........................)

ង-ឈ្មោះម្ចាស់បំណុល........................(អាសយដ្ឋាន.....................
.......................................................................)

ច-ឈ្មោះកូនបំណុល........................(អាសយដ្ឋាន.....................
.......................................................................)

ឯកសារភ្ជាប់ជាមួយ :

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

**ប្រការ ២១ : លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងដោយផ្អែកលើមាត្រា ៥៧០ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬបើពាក្យសុំអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុត្រូវបានដក ឬ បើដីកាសម្រេចលុបចោលការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុដែលត្រូវបានចាត់ចែងជាបណ្តោះអាសន្ន បានបង្កើតអានុភាពក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ច ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុនោះ ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:....................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ)

ក-អត្តសញ្ញាណនៃអចលនវត្ថុ..........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ........
............... (អាសយដ្ឋាន ..........................................................)

គ-គោលបំណងនៃការចុះបញ្ជី ..................................(លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ចំណុច“ក” )

ឃ-មូលហេតុ ......................(ការដកពាក្យសុំដីកាចាត់ចែងជាបណ្តោះអាសន្ន

ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬ ការដកពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុចុះថ្ងៃទី......ខែ.........ឆ្នាំ......... ឬដីកាសម្រេចលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុលេខ...... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ.......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ....................................)

ង-ឈ្មោះម្ចាស់បំណុល.......................................(អាសយដ្ឋាន............ ..........................................................)

ច-ឈ្មោះកូនបំណុល.........................................(អាសយដ្ឋាន........... ..........................................................)

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុត្រូវបានដក :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

៣-ក្នុងករណីការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុត្រូវបានលុបចោល :

ក-ក្នុងករណីដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង

អចលនវត្ថុ ត្រូវបានលុបចោលដោយផ្អែកលើមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព) មាត្រា ៥៥៩ (ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស) និង មាត្រា ៥៦១ (បណ្តឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដោយផ្អែកលើមាត្រា ៥៦៤ ( ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ)កថា-ខណ្ឌទី ១ ចំណុច “ក” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ខ-ការលុបចោលដោយផ្អែកលើមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ឆ” ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

គ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច “ង” (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជា ដែលមានខ្លឹមសារថា មិនអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬ ការដកពាក្យសុំដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ឬ ការដកពាក្យសុំអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ឃ-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤(ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) និងមាត្រា ៣៧០

(ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ឆ" (ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ យោងតាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រមចុងក្រោយនៃបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ដែលបង្គាប់ឱ្យលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ង-ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយជាអាទិ៍ ) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ ចំណុច "ឆ" (ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុយោងតាមមាត្រា ៣៦៧ កថាខណ្ឌទី ២ ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ តាមមាត្រា ៥៦៤ ឬ អនុសារសាលក្រមចុងក្រោយ នៃបណ្ដឹងតវ៉ារបស់តតិយជន ដែលបង្គាប់ឱ្យលុបចោលការចាត់ចែងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ច-ការលុបចោលដោយផ្អែកលើមាត្រា ៥៧០ (ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន) មាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) កថាខណ្ឌទី៤ និងមាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្ត ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ។

ឆ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា ៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ។

# ផ្នែកទី ៣

# នីតិវិធីនៃការចុះបញ្ជី

## កថាភាគទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ២២: នីតិវិធីនៃការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

ក-ចំពោះការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ ការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិ ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងកម្មសិទ្ធិ ត្រូវសរសេរនៅក្នុង "សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់(Column)ត្រង់ " បន្ទុកលើអចលនវត្ថុ " ។

ខ-ចំពោះការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ការរឹបអូសជាបណ្តោះអាសន្ននូវសិទ្ធិជួលអចិន្ត្រៃយ៍ ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរនៅក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍" នៅក្នុងខ្ទង់(Column)ត្រង់ "បន្ទុកលើអចលនវត្ថុ " ។

គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសផលុបភោគ ការរឹបអូសជាបណ្តោះអាសន្ន នូវផលុបភោគ ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងផលុបភោគ ត្រូវសរសេរនៅក្នុង"សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ។

## កថាភាគទី ២

## របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ប្រការ ២៣: របៀបចុះបញ្ជីអំពីការរឹបអូសក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្តាក់ដែលបានកំណត់ក្នុងប្រការ ៧ (លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសចំពោះអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃការរឹបអូស :

ក-ចំពោះការរឹបអូសកម្មសិទ្ធិត្រូវសរសេរក្នុង"សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់(Column) ត្រង់"បន្ទុកលើអចលនវត្ថុ" :

" ត្រូវបានរឹបអូសកម្មសិទ្ធិ តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី .....ខែ........ឆ្នាំ.......របស់តុលាការអនុវត្ត........ហត្ថលេខា.Aj.....(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)" ។

ខ-ចំពោះការរឹបអូសចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់"បន្ទុកលើអចលនវត្ថុ" :

" ត្រូវបានរឹបអូសចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ............តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ....ឆ្នាំ......របស់តុលាការអនុវត្ត.............ហត្ថលេខា.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)" ។

គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" :

" ត្រូវបានរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់តុលាការអនុវត្ត.........ហត្ថលេខា.Aj... (ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

ឃ-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" :

" ត្រូវបានរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ.....................តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ........ចុះថ្ងៃទី...ខែ...ឆ្នាំ.....របស់តុលាការអនុវត្ត........ ហត្ថលេខា.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

ង-ចំពោះការចុះបញ្ជីអំពីការរឹបអូសផលុបភោគ ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុប-ភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" :

" ត្រូវបានរឹបអូសផលុបភោគតាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី .....ខែ......ឆ្នាំ.....របស់តុលាការអនុវត្ត................ហត្ថលេខា.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ ) " ។

ច-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកផលុបភោគដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" :

“ ត្រូវបានរឹបអូសចំណែកផលុបភោគរបស់ឈ្មោះ...........តាមដីកាសម្រេចចាប់ផ្តើមលក់ដោយបង្គាប់លេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ........របស់តុលាការអនុវត្ត.........ឈរ.Aj... ( ជាទឹកក្រហម ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) ” ។

**ប្រការ ២៤ : របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្តុកផ្តាក់ដែលបានកំណត់ក្នុងប្រការ ៨ (លិខិតផ្តុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសចំពោះអចលនវត្ថុ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការលុបទៅតាមប្រភេទនៃការរឹបអូស :

១-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង “សៀវភៅគោលបញ្ជីដីធ្លី” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពីការ “ រឹបអូសកម្មសិទ្ធិ ឬ រឹបអូសចំណែកកម្មសិទ្ធិអវិភាគ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.......ដែលតុលាការ................បានចេញដីកាសម្រេចលេខ......ចុះថ្ងៃទី......ខែ......ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.........ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....របស់តុលាការអនុវត្ត.........ឈរ.Aj... ឬតាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី.....ខែ......ឆ្នាំ......(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

២-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួមត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពីការ “ រឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ រឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.......ដែលតុលាការ.................បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់តុលាការអនុវត្ត...........ឈរ.Aj... ឬ តាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី....ខែ.....ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

៣-ចំពោះការចុះបញ្ជីអំពីការលុបការរឹបអូសផលុបភោគ ឬ ចំណែកផលុបភោគ ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីផលុបភោគ" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹងការចុះបញ្ជីអំពីការ " រឹបអូសផលុបភោគ ឬ រឹបអូសចំណែកផលុបភោគ " ដោយត្រូវសរសេរថា :

" ត្រូវបានលុបការរឹបអូស......ដែលតុលាការ.......បានចេញដីកាសម្រេចលេខ.....ចុះថ្ងៃទី....ខែ......ឆ្នាំ......តាមដីកាសម្រេចលុបចោលលេខ.......ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....របស់តុលាការអនុវត្ត..............លរ.Aj... ឬ តាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី.....ខែ.....ឆ្នាំ......(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

**ប្រការ ២៥ : របៀបចុះបញ្ជីអំពីការផ្ទេរសិទ្ធិ អំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ អំពីការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្ដោះអាសន្ន អំពីការលុបការចុះបញ្ជី អំពីការការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ៩ (លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការផ្ទេរផលុបភោគ តាមការលក់ដោយបង្ខំ ដោយផ្អែកលើមាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការផ្ទេរ ឬ ការលុបទៅតាមប្រភេទដូចខាងក្រោម :

**១-ចុះបញ្ជីអំពីការផ្ទេរសិទ្ធិ :**

ក-ចំពោះការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" :

-នៅក្នុងខ្ទង់ (Column) ត្រង់ " លេខាធារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរកម្មសិទ្ធិឱ្យទៅឈ្មោះ....................តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ......... និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.............នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ " នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ " ដោយត្រូវសរសេរថា :



ಗಿ ೫

“ ឈ្មោះ............(គឺឈ្មោះរបស់ម្ចាស់កម្មសិទ្ធិថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ.....ខែ.....ឆ្នាំ......និងទីកន្លែងកំណើត(គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់កម្មសិទ្ធិថ្មី )”(ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “សាវតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ........និងឈ្មោះ.....(គឺឈ្មោះឪពុកនិងម្តាយរបស់ម្ចាស់កម្មសិទ្ធិថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

ខ-ចំពោះការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុង “ សៀវភៅគោលបញ្ជីដីថ្មី ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ.........ឱ្យទៅឈ្មោះ.............តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...............នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ ” ដោយត្រូវសរសេរថា :

“ ឈ្មោះ.....................(គឺឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ឡើងវិញ)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពី បីនាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះតំណាងម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ ហើយត្រូវសរសេរឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ......ខែ.......ឆ្នាំ.....និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់តំណាងម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ ) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “សារតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ..........និងឈ្មោះ...........(គឺឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មីទាំងអស់) (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់កម្មសិទ្ធិអវិភាគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះឪពុក និងម្ដាយរបស់អ្នកតំណាងម្ចាស់កម្មសិទ្ធិអវិភាគ ហើយសរសេរឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

គ-ចំពោះការចុះបញ្ជីអំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរក្នុង “សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ.........ឱ្យទៅឈ្មោះ..........តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.....................នៅថ្ងៃទី.....ខែ.....ឆ្នាំ.....លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

-នៅក្នុងខ្ទង់ (Column) ត្រង់ “នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ” ដោយត្រូវសរសេរថា :

“ ឈ្មោះ.......(គឺឈ្មោះរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

-នៅក្នុងខ្ទង់(Column)ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ....ខែ.....ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ថ្មី ” (ជាទឹកខៀវ ឬ ខ្មៅ) ។

- នៅក្នុងខ្ទង់ (Column)ត្រង់ “សារតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ..........និងឈ្មោះ........... (គឺឈ្មោះឪពុក និងម្តាយរបស់ម្ចាស់សិទ្ធិផ្លូវលអចិន្ត្រៃយ៍ថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ ) ។

ឃ-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង“សៀវភៅចុះបញ្ជីសិទ្ធិផ្លូវលអចិន្ត្រៃយ៍ ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍របស់ឈ្មោះ.........ឱ្យទៅឈ្មោះ......តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.....................
នៅថ្ងៃទី......ខែ......ឆ្នាំ......... លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

នៅក្នុងខ្ទង់ (Column) ត្រង់ “ នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ ” ដោយត្រូវសរសេរថា :

“ ឈ្មោះ..................(គឺឈ្មោះម្ចាស់ចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់ឡើងវិញ) (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់សិទ្ធិផ្លូវលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

- នៅក្នុងខ្ទង់ (Column) ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរថា :

“ ថ្ងៃ.......ខែ.....ឆ្នាំ......និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ឈ្មោះម្ចាស់ចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់សិទ្ធិផ្លូវលអចិន្ត្រៃយ៍ណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែកសិទ្ធិផ្លូវលអចិន្ត្រៃយ៍ទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

-នៅក្នុងខ្ទង់ (Column)ត្រង់ “សារតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ..........និងឈ្មោះ...........(គឺឈ្មោះឪពុក និងម្ដាយរបស់ម្ចាស់ចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួមថ្មីទាំងអស់)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានម្ចាស់សិទ្ធិផ្លូវអចិន្ត្រៃយ៍ចាប់ពី បីនាក់ ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះឪពុក និងម្ដាយរបស់អ្នកតំណាងម្ចាស់សិទ្ធិផ្លូវអចិន្ត្រៃយ៍ ហើយសរសេរឈ្មោះឪពុកនិងម្ដាយរបស់ម្ចាស់សិទ្ធិផ្លូវអចិន្ត្រៃយ៍ទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) ” ។

ង-ចំពោះការចុះបញ្ជីអំពីការផ្ទេរផលុបភោគ ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីផលុបភោគ ” :

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ ” ដោយត្រូវសរសេរថា :

“ ត្រូវបានផ្ទេរផលុបភោគរបស់ឈ្មោះ.............ឱ្យទៅឈ្មោះ...............តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ....និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ.............នៅថ្ងៃទី..... ខែ......ឆ្នាំ.......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

- នៅក្នុងខ្ទង់(Column)ត្រង់ “នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ” ដោយត្រូវសរសេរថា :

“ ឈ្មោះ.............(គឺឈ្មោះរបស់ផលុបភោគីថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ ) ។

- នៅក្នុងខ្ទង់(Column)ត្រង់ “ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ” ដោយត្រូវសរសេរ ថា :

“ ថ្ងៃ..........ខែ.......ឆ្នាំ.......និងទីកន្លែងកំណើត(គឺថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ផលុបភោគីថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ ) ។

- នៅក្នុងខ្ទង់ (Column)ត្រង់ “សារតា” ដោយត្រូវសរសេរថា :

“ ឈ្មោះ............និងឈ្មោះ............(គឺឈ្មោះឪពុក និងម្ដាយរបស់ផលុបភោគីថ្មី) ” (ជាទឹកខៀវ ឬ ខ្មៅ) ។

ច-ចំពោះការចុះបញ្ជីអំពីការផ្ទេរចំណែកផលុបភោគដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីផលុបភោគ ”

-នៅក្នុងខ្ទង់ (Column) ត្រង់ “ លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រម



ᛉ ᛋ

តុលាការ " ដោយត្រូវសរសេរថា :

" ត្រូវបានផ្ទេរចំណែកផលុបភោគរបស់ឈ្មោះ..... ឱ្យទៅឈ្មោះ.........តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ................នៅថ្ងៃទី.....ខែ.....ឆ្នាំ......លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

-នៅក្នុងខ្ទង់ (Column)ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ដោយត្រូវសរសេរថា :

" ឈ្មោះ............. (គឺឈ្មោះម្ចាស់ចំណែកផលុបភោគដែលជាសិទ្ធិរួមថ្មីទាំងអស់ឡើងវិញ)(ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានឈ្មោះម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរឈ្មោះតំណាងម្ចាស់ផលុបភោគណាម្នាក់ ហើយសរសេរឈ្មោះម្ចាស់ចំណែកផលុបភោគទាំងអស់នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) "។

-នៅក្នុងខ្ទង់ (Column)ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត " ដោយត្រូវសរសេរថា :

" ថ្ងៃ......ខែ......ឆ្នាំ.....និងទីកន្លែងកំណើត (គឺថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរបស់ម្ចាស់ចំណែកផលុបភោគថ្មីទាំងអស់) (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណី មានឈ្មោះម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដី ត្រូវសរសេរ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់តំណាងម្ចាស់ចំណែកផលុបភោគណាម្នាក់ ហើយសរសេរថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតម្ចាស់ចំណែកផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ ) " ។

-នៅក្នុងខ្ទង់ (Column) ត្រង់ "សារតា" ដោយត្រូវសរសេរថា :

" ឈ្មោះ........និងឈ្មោះ.......(គឺឈ្មោះឪពុក និងម្តាយរបស់ឈ្មោះម្ចាស់ចំណែកផលុបភោគដែលជាសិទ្ធិរួមថ្មីទាំងអស់ (ជាទឹកខៀវ ឬ ខ្មៅ) ។

ប៉ុន្តែបើក្នុងករណីមានម្ចាស់ចំណែកផលុបភោគចាប់ពីបីនាក់ឡើងទៅ រដ្ឋបាលសុរិយោដីត្រូវសរសេរឈ្មោះឪពុក និងម្តាយរបស់អ្នកតំណាងម្ចាស់ចំណែកផលុបភោគ ហើយសរសេរឈ្មោះឪពុក និងម្តាយរបស់ម្ចាស់ចំណែកផលុបភោគទាំងអស់ នៅក្នុងលិខិតដាច់ដោយឡែក រួចដាក់នៅក្នុងឯកសារនៃសំណុំរឿងចុះបញ្ជីនោះ) " ។

**២-ចុះបញ្ជីអំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបាត់បង់អានុភាពដោយការលក់ :**

-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបាត់បង់អានុភាពដោយការលក់ គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ (Column) ដែលលទ្ធកម្មសិទ្ធិត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ត្រូវបានលុបការចុះបញ្ជីអំពី.......(ការផ្ទេរកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬហ៊ីប៉ូតែក ជាអាទិ៍) តាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ............នៅថ្ងៃទី.....ខែ....ឆ្នាំ.....លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " ។

**៣-ចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងដែលបានបាត់បង់អានុភាពដោយការលក់ :**

-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង ដែលបានបាត់បង់អានុភាពដោយការលក់ គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ ដែលការចាត់ចែងជាបណ្ដោះអាសន្នត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានលុបចោលតាមដីកាសម្រេចអនុញ្ញាតឱ្យលក់ លេខ...........និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...........នៅថ្ងៃទី.....ខែ.....ឆ្នាំ.....លរ.Aj...(ជាទឹកខៀវ ឬ ខ្មៅ) " រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម) " ។

**៤-ចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន ។**

-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្ន គឺត្រូវចុះបញ្ជីនៅក្នុងខ្ទង់ (Column) ដូចគ្នានឹងខ្ទង់ (Column) ដែលការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្នត្រូវបានចុះបញ្ជី ដោយត្រូវសរសេរថា :

" ការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្ដោះអាសន្នត្រូវបានលុបចោលតាមដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ............និងអ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ..............នៅថ្ងៃទី.....ខែ.......ឆ្នាំ........លរ.Aj... (ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) " :

## កថាភាគទី ៣
## របៀបចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

**ប្រការ ២៦ :** របៀបចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្តាក់ដែលបានកំណត់ក្នុងប្រការ ១០ (លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២០ មាត្រា ៥១១ និងមាត្រា ៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃការរឹបអូស :

**ក-ចំពោះការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ** ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសកម្មសិទ្ធិតាមដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ.........ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....(ផ្អែកលើសិទ្ធិប្រាតិភោគ)របស់តុលាការអនុវត្ត....លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកខៀវ ឬ ខ្មៅ) " ។

**ខ-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column)ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ...................... តាមដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ.......ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត.....លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**គ-ចំពោះការចុះបញ្ជីអំពីការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍** ត្រូវសរសេរក្នុង "សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍" នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា :

" ត្រូវបានរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍តាមដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ..... ចុះថ្ងៃទី.....ខែ......ឆ្នាំ......(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត.........លរ.Aj... (ជាទឹកក្រហម)រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)" ។

**ឃ-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍** ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើ

អចលនវត្ថុ " ដោយត្រូវសរសេរថា ៖

" ត្រូវបានរឹបអូសចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ........... តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ.......(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត........លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកខៀវ ឬ ខ្មៅ) " ។

**ង-ចំពោះការចុះបញ្ជីអំពីការរឹបអូសផលុបភោគ** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់(Column)ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា ៖

" ត្រូវបានរឹបអូសផលុបភោគតាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.....ចុះថ្ងៃទី....ខែ....ឆ្នាំ.... (ផ្អែកលើសិទ្ធិប្រាតិភោគ)របស់តុលាការអនុវត្ត.......លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ)"។

**ច-ចំពោះការចុះបញ្ជីអំពីការរឹបអូសចំណែកផលុបភោគដែលជាសិទ្ធិរួម** ត្រូវសរសេរក្នុង " សៀវភៅចុះបញ្ជីផលុបភោគ " នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា ៖

" ត្រូវបានរឹបអូសចំណែកផលុបភោគរបស់ឈ្មោះ...........តាមដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ......ចុះថ្ងៃទី...ខែ......ឆ្នាំ........(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត............លរ.Aj...(ជាទឹកក្រហម) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬ ខ្មៅ) " ។

**ប្រការ ២៧** ៖ **របៀបចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ**

នៅពេលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្ដាក់ដែលបានកំណត់ក្នុងប្រការ ១១ (លិខិតផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ដោយផ្អែកលើមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គឺត្រូវចុះបញ្ជីអំពីការលុបទៅតាមប្រភេទនៃការលុបការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ ៖

**ក-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ** ត្រូវសរសេរក្នុង " សៀវភៅគោលបញ្ជីដីធ្លី " នៅក្នុងខ្ទង់ ( Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដូចគ្នានឹង ការចុះបញ្ជីអំពី " ការរឹបអូសកម្មសិទ្ធិ ឬ ការរឹបអូសចំណែកកម្ម

សិទ្ធិអាវិភាគ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស..........ដែលតុលាការ............បានចេញដីកាសម្រេច លេខ....ចុះថ្ងៃទី....ខែ....ឆ្នាំ....តាមដីកាសម្រេចលុបចោលលេខ....ចុះថ្ងៃ....ខែ.....ឆ្នាំ...... របស់តុលាការអនុវត្ត...........លរ.Aj... ឬតាមការដកពាក្យរបស់ម្ចាស់បំណុល នៃការអនុវត្ត ចុះថ្ងៃទី....ខែ.....ឆ្នាំ.....(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម) ” ។

ខ-ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិផ្លូវអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុង “ សៀវភៅចុះបញ្ជីសិទ្ធិផ្លូវអចិន្ត្រៃយ៍ ” នៅក្នុងខ្ទង់ (Column) ត្រង់ “បន្ទុកលើអចលនវត្ថុ” ដូចគ្នានឹងការចុះបញ្ជីអំពី “ ការរឹបអូសសិទ្ធិផ្លូវអចិន្ត្រៃយ៍ ឬ ការរឹបអូសចំណែកសិទ្ធិផ្លូវអចិន្ត្រៃយ៍ ” ដោយត្រូវសរសេរថា :

“ ត្រូវបានលុបការរឹបអូស.........ដែលតុលាការ..............បានចេញដីកាសម្រេច លេខ.....ចុះថ្ងៃទី.....ខែ.......ឆ្នាំ.........តាមដីកាសម្រេចលុបចោលលេខ......ចុះថ្ងៃទី...... ខែ.....ឆ្នាំ.......របស់តុលាការអនុវត្ត...............លរ. Aj... ឬតាមការដកពាក្យរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី....ខែ.....ឆ្នាំ......“(ជាទឹកខៀវ ឬ ខ្មៅ) រួចបោះត្រាលេខាធិការ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម) ” ។

ប្រការ ៣៩ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតផលុបភោគ ........ ២១

ប្រការ ៤០ - ពាក្យសុំចុះបញ្ជី អំពីការផ្ទេរផលុបភោគ ........ ២២

ប្រការ ៤១ - ពាក្យសុំចុះបញ្ជី អំពីការផ្ទេរចំណែកផលុបភោគអវិភាគ ........ ២២

ប្រការ ៤២ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេល តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ ការសន្យាពិសេសអំពីផលុបភោគ ........ ២៣

ប្រការ ៤៣ - ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវផលុបភោគ ឬ ចំណែកផលុបភោគ ........ ២៤

ប្រការ ៤៤ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីផលុបភោគ ........ ២៥


### ផ្នែកទី ៥- ពាក្យសុំចុះបញ្ជី អំពីសេវភាព


ប្រការ ៤៥ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតសេវភាព ........ ២៦

ប្រការ ៤៦ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់ថ្លៃថ្នូរ ឬ ការសន្យាពិសេសអំពីសេវភាព ........ ២៧

ប្រការ ៤៧ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសេវភាព ........ ២៨


### ផ្នែកទី ៦- ពាក្យសុំចុះបញ្ជី អំពីឯកសិទ្ធិ


ប្រការ ៤៨ - ពាក្យសុំចុះបញ្ជី អំពីឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ ........ ២៩

ប្រការ ៤៩ - ពាក្យសុំចុះបញ្ជី អំពីការផ្ទេរឯកសិទ្ធិ ........ ៣០

ប្រការ ៥០ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីឯកសិទ្ធិ ........ ៣១

**ផ្នែកទី ៧- ពាក្យសុំចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ**

ប្រការ ៥១ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ ........ ៣២

ប្រការ ៥២ - ពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ ........ ៣៣

ប្រការ ៥៣ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត ........ ៣៤

ប្រការ ៥៤ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវសិទ្ធិលើការបញ្ចាំ ........ ៣៥

ប្រការ ៥៥ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ ........ ៣៦

**ផ្នែកទី ៨- ពាក្យសុំចុះបញ្ជី អំពីហ៊ីប៉ូតែក**

ប្រការ ៥៦ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក ........ ៣៧

ប្រការ ៥៧ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត ........ ៣៨

ប្រការ ៥៨ - ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក ........ ៣៨

ប្រការ ៥៩ - ពាក្យសុំចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម ........ ៣៩

ប្រការ ៦០ - ពាក្យសុំចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក ........ ៤០

ប្រការ ៦១ - ពាក្យសុំចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក ........ ៤១

ប្រការ ៦២ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក ........ ៤២

ប្រការ ៦៣ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវហ៊ីប៉ូតែក ........ ៤៣

ប្រការ ៦៤ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក ........ ៤៤

**ផ្នែកទី ៩- ពាក្យសុំចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

ប្រការ ៦៥ - ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៤៥

ប្រការ ៦៦ - ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៤៦

ប្រការ ៦៧ - ពាក្យសុំចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៤៧

ប្រការ ៦៨ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមា ទាក់ទងនឹងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៤៨

ប្រការ ៦៩ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៤៨

ប្រការ ៧០ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៤៩

ប្រការ ៧១ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៥០

**ផ្នែកទី ១០- ពាក្យសុំចុះបញ្ជី អំពីសិទ្ធិបន្ទាប់បន្សំមួយចំនួន ដែលពាក់ព័ន្ធទៅនឹងសិទ្ធិប្រត្យក្ស**

ប្រការ ៧២ - ពាក្យសុំចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ ........ ៥១

ប្រការ ៧៣ - ពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ........ ៥២

ប្រការ ៧៤ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរអំឡុងពេលហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ........ ៥២

ប្រការ ៧៥ - ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវអំឡុងពេលហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ........ ៥៣

ប្រការ ៧៦ - ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ........ ៥៤

**ផ្នែកទី ១១- ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ និងការកែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ**
ប្រការ ៧៧ - ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ ........ ៥៥
ប្រការ ៧៨ - ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ ........ ៥៦

**ជំពូកទី ៥- ការចុះបញ្ជី**
**ផ្នែកទី ១- បទប្បញ្ញត្តិទូទៅ**
ប្រការ ៧៩ - ការចុះបញ្ជីបន្ថែម ........ ៥៧
ប្រការ ៨០ - ការចុះបញ្ជីឈ្មោះម្ចាស់សិទ្ធិអវិភាគ និងចំណែក ........ ៥៧
ប្រការ ៨១ - តារាងឈ្មោះម្ចាស់សិទ្ធិអវិភាគ ........ ៥៧
ប្រការ ៨២ - តារាងប្រាតិភោគរួម ........ ៥៨
ប្រការ ៨៣ - លេខរៀង ........ ៥៨
ប្រការ ៨៤ - ការចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីជានាបំណុលអណ្តែត ........ ៥៨
ប្រការ ៨៥ - ការចុះបញ្ជីដោយឆន្ទានុសិទ្ធិរបស់មន្ត្រីចុះបញ្ជី ........ ៥៩
ប្រការ ៨៦ - ការចុះបញ្ជី អំពីសេវភាព ........ ៥៩
ប្រការ ៨៧ - គំនូសបង្ហាញទីតាំងសេវភាព ........ ៦០
ប្រការ ៨៨ - ការដកពាក្យសុំចុះបញ្ជី ........ ៦០
**ផ្នែកទី ២- របៀបទូទៅនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្ស**
ប្រការ ៨៩ - របៀបទូទៅនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្ស ........ ៦០
**កថាភាគទី ១- របៀបចុះបញ្ជីអំពីកម្មសិទ្ធិ**
ប្រការ ៩០ - របៀបចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ ........ ៦១
ប្រការ ៩១ - របៀបចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ........ ៦៣
ប្រការ ៩២ - របៀបចុះបញ្ជី អំពីការកែតម្រូវកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ........ ៦៥
ប្រការ ៩៣ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ ........ ៦៦
**កថាភាគទី ២- របៀបចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍**
ប្រការ ៩៤ - របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ........ ៦៦
ប្រការ ៩៥ - របៀបចុះបញ្ជី អំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ........ ៦៧
ប្រការ ៩៦ - របៀបចុះបញ្ជី អំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ........ ៦៨
ប្រការ ៩៧ - របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បន្ត ........ ៧០
ប្រការ ៩៨ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវសិទ្ធិជួលអចិន្ត្រៃយ៍ ........ ៧០
ប្រការ ៩៩ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍ ........ ៧២
**កថាភាគទី ៣- របៀបចុះបញ្ជី អំពីផលុបភោគ**
ប្រការ ១០០ - របៀបចុះបញ្ជី អំពីការបង្កើតផលុបភោគ ........ ៧៣

ប្រការ ១០១ - របៀបចុះបញ្ជី អំពីការផ្ទេរផលុបភោគ ..................................................................... ៧៣
ប្រការ ១០២ - របៀបចុះបញ្ជី អំពីការផ្ទេរចំណែកផលុបភោគ ........................................................ ៧៥
ប្រការ ១០៣ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវផលុបភោគ ..................................... ៧៦
ប្រការ ១០៤ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីផលុបភោគ ........................................... ៧៨

**កថាភាគទី ៤- របៀបចុះបញ្ជី អំពីសេវភាព**

ប្រការ ១០៥ - របៀបចុះបញ្ជី អំពីការបង្កើតសេវភាព ..................................................................... ៧៩
ប្រការ ១០៦ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវសេវភាព ............................................. ៧៩
ប្រការ ១០៧ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសេវភាព .............................................. ៨២

**កថាភាគទី ៥- របៀបចុះបញ្ជី អំពីឯកសិទ្ធិ**

ប្រការ ១០៨ - របៀបចុះបញ្ជី អំពីឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ ..................................................................................................... ៨២
ប្រការ ១០៩ - របៀបចុះបញ្ជី អំពីការផ្ទេរឯកសិទ្ធិ ........................................................................ ៨៣
ប្រការ ១១០ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីឯកសិទ្ធិ ............................................... ៨៣

**កថាភាគទី ៦- របៀបចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ**

ប្រការ ១១១ - របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ ....................................................... ៨៣
ប្រការ ១១២ - របៀបចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ ........................................................... ៨៣
ប្រការ ១១៣ - របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត ................................................. ៨៤
ប្រការ ១១៤ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវសិទ្ធិលើការបញ្ចាំ ................................ ៨៤
ប្រការ ១១៥ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ ................................ ៨៦

**កថាភាគទី ៧- របៀបចុះបញ្ជី អំពីហ៊ីប៉ូតែក**

ប្រការ ១១៦ - របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក ................................................................... ៨៦
ប្រការ ១១៧ - របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត ............................................................ ៨៦
ប្រការ ១១៨ - របៀបចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក ....................................................................... ៨៦
ប្រការ ១១៩ - របៀបចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម ........................................................ ៨៧
ប្រការ ១២០ - របៀបចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក ............................. ៨៧
ប្រការ ១២១ - របៀបចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក .......... ៨៧
ប្រការ ១២២ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក ..................................................... ៨៧
ប្រការ ១២៣ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវហ៊ីប៉ូតែក ............................................. ៨៨
ប្រការ ១២៤ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក .............................................. ៨៩

**កថាភាគទី ៨- របៀបចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

ប្រការ ១២៥ - របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ............................ ៨៩
ប្រការ ១២៦ - របៀបចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ................................ ៩០
ប្រការ ១២៧ - របៀបចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ..... ៩០
ប្រការ ១២៨ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........................... ៩០
ប្រការ ១២៩ - របៀបចុះបញ្ជី អំពីការព្រមព្រៀងគ្នារបស់សន្តតិជននៃម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានា

បំណុលអណ្តែត និង/ឬ កូនបំណុល ............................................................. ៩១
ប្រការ ១៣០ - របៀបចុះបញ្ជី អំពីកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ............................................................. ៩១
ប្រការ ១៣១ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ........ ៩១
**កថាភាគទី ៩- របៀបចុះបញ្ជី អំពីសិទ្ធិបន្ទាប់បន្សំមួយចំនួនដែលពាក់ព័ន្ធទៅនឹងសិទ្ធិប្រត្យក្ស**
ប្រការ ១៣២ - របៀបចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ ............................................................. ៩២
ប្រការ ១៣៣ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ ................ ៩២
ប្រការ ១៣៤ - របៀបចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ........................ ៩២
ប្រការ ១៣៥ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេលហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ............................................................. ៩២
ប្រការ ១៣៦ - របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ...... ៩៤
**កថាភាគទី ១០- របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ**
ប្រការ ១៣៧ - របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ ............................................................. ៩៤

**ជំពូកទី ៦- នីតិវិធីនៃការសុំមើល និងការសុំចេញលិខិតបញ្ជាក់អំពីព័ត៌មានដែលបានចុះបញ្ជី**
ប្រការ ១៣៨ - របៀបដាក់ពាក្យសុំមើល និងសុំឱ្យបញ្ជាក់ ............................................................. ៩៥
ប្រការ ១៣៩ - ការអនុញ្ញាតឲ្យមើល និងការចេញលិខិតបញ្ជាក់ ............................................................. ៩៥

**ជំពូកទី ៧- លិខិតបញ្ជាក់ការចុះបញ្ជីសិទ្ធិប្រាតិភោគ**
ប្រការ ១៤០ - លិខិតបញ្ជាក់ការចុះបញ្ជីសិទ្ធិប្រាតិភោគ ............................................................. ៩៦

**ជំពូកទី ៨- អវសានប្បញ្ញត្តិ**
ប្រការ ១៤១ - កាលបរិច្ឆេទ នៃការអនុវត្ត ............................................................. ៩៦
ប្រការ ១៤២ - និរាករណ៍ នៃបទប្បញ្ញត្តិដែលផ្ទុយ ............................................................. ៩៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ: ៣០៨ ប្រក.ដនស.-យក/១៣

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

*រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣*

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សនាក់ទងនឹងក្រមរដ្ឋប្បវេណី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
- តាមការចាំបាច់ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីអចលនវត្ថុឲ្យបានត្រឹមត្រូវទៅតាមក្រមរដ្ឋប្បវេណី។

**ប្រការ ២ : គោលបំណង**

ប្រកាសនេះ មានគោលបំណងបញ្ញត្តនូវនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជី និងនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដោយយោងតាមក្រមរដ្ឋប្បវេណី។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ ត្រូវយកមកអនុវត្តចំពោះដី ដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ហើយក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះដីដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ។

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើការចុះបញ្ជីដូចខាងក្រោម ៖

ក– ការផ្ទេរ ការផ្លាស់ប្តូរ ការកែតម្រូវ ការរំលត់កម្មសិទ្ធិ

ខ– ការបង្កើត ការផ្ទេរ ការផ្លាស់ប្តូរ ការកែតម្រូវ ការរំលត់សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក

គ– ការបង្កើត ការផ្លាស់ប្តូរ ការកែតម្រូវ និងការរំលត់សេវភាព

**ប្រការ ៤ : និយមន័យ**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

១– បុគ្គល គឺសំដៅទៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គល ។

២– ចំណុចដែលត្រូវចុះបញ្ជី គឺសំដៅទៅលើចំណុចដែលត្រូវចុះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះ ។

៣– បុគ្គលមានសិទ្ធិចុះបញ្ជី គឺសំដៅទៅលើបុគ្គល ដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី ។

៤– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី គឺសំដៅទៅលើបុគ្គលដែលទទួលនូវការប៉ះពាល់ផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី ។

៥– បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺសំដៅទៅលើបុគ្គលមានសិទ្ធិចុះបញ្ជី ឬ បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ឬ បុគ្គលផ្សេងទៀតដែលត្រូវប្រើសិទ្ធិចុះបញ្ជី ឬ ត្រូវអនុវត្តកាតព្វកិច្ចចុះបញ្ជី ។

៦– បុគ្គលទទួលបន្តជាសកល គឺសំដៅទៅលើបុគ្គលដែលទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ចទាំងអស់ដែលបុគ្គលនោះមានតាមរយៈសន្តតិកម្ម ឬ ការរួមបញ្ចូលនៃនីតិបុគ្គល ។

៧– ការចុះបញ្ជី អំពីការផ្លាស់ប្តូរ គឺសំដៅទៅលើការចុះបញ្ជី ដែលត្រូវធ្វើឡើង ក្នុងករណីដែលមានការផ្លាស់ប្តូរចំណុចណាមួយ ដែលបានចុះបញ្ជីរួចហើយ ដើម្បីផ្លាស់ប្តូរនូវចំណុចនោះ។

៨- ការចុះបញ្ជី អំពីការកែតម្រូវ គឺសំដៅទៅលើការចុះបញ្ជី ដែលត្រូវធ្វើឡើងក្នុងករណីដែលមានកំហុស ឬ ការខកខានមិនបានចុះចំណុចណាមួយ ដែលត្រូវចុះបញ្ជី ដើម្បីកែតម្រូវនូវចំណុចនោះ។

៩- ការចុះបញ្ជីបន្ថែម គឺជាការចុះបញ្ជីសិទ្ធិ ដែលចាំបាច់សម្រាប់ផ្សព្វផ្សាយជាសាធារណៈ ដោយមានទំនាក់ទំនងជាមួយការចុះបញ្ជីចម្បង ដែលបានធ្វើរួចហើយ។

១០- លិខិតផ្ទុកផ្ដាក់ដើម្បីចុះបញ្ជី គឺជាលិខិតរបស់តុលាការ ឬ របស់ស្ថាប័នផ្សេងទៀត ដែលបានផ្ញើមករដ្ឋបាលសុរិយោដី ដើម្បីស្នើសុំឲ្យធ្វើនីតិវិធីចុះបញ្ជី ។

## ប្រការ ៥ : ស្ថាប័នមានសមត្ថកិច្ច

១-ស្ថាប័ន ដែលមានសមត្ថកិច្ចទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ តាមន័យនៃប្រកាសនេះ គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ ។

រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត និងរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតសៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងៗទៀត ។

រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបានទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវផ្ញើពាក្យសុំនោះ និងឯកសារពាក់ព័ន្ធទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ ដោយគ្មានការយឺតយ៉ាវ ។

២-ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ តាមន័យនៃប្រកាសនេះ គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ ។

## ប្រការ ៦ : ពាក្យសុំចុះបញ្ជី និងការចុះបញ្ជី

ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬ លិខិតផ្ទុកផ្ដាក់ ។

ការចុះបញ្ជីនូវចំណុចដែលត្រូវចុះបញ្ជី គឺត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជី ដែលពាក់ព័ន្ធ។

## ប្រការ ៧ : លំដាប់ នៃការចុះបញ្ជី

រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលជាស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវចុះលេខរៀងទៅតាមលំដាប់នៃការទទួលពាក្យសុំ នៅលើពាក្យសុំចុះបញ្ជីដែលទទួលបានដោយផ្ទាល់ ឬ ទទួលបានពីរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ នៅលើលិខិតផ្ទុកផ្ដាក់ ដែលបានទទួលពីតុលាការ ឬ ពីស្ថាប័ន ដែលមានសមត្ថកិច្ច ផ្សេងទៀត ។

ក្នុងករណីមានការដាក់ពាក្យសុំចុះបញ្ជីច្រើនទៅលើអចលនវត្ថុតែមួយ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលជាស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវចុះបញ្ជីទៅតាមលំដាប់លេខរៀងជាបន្តបន្ទាប់ នៃការទទួលពាក្យសុំ និងកាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជី ឬ លិខិតផ្ទុកផ្ដាក់ ដែលបានទទួលពីតុលាការ ឬ ពីស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ។

## ប្រការ ៨ : លំដាប់អាទិភាព នៃសិទ្ធិ

១- លំដាប់អាទិភាព នៃសិទ្ធិដែលបានចុះបញ្ជីនៅលើអចលនវត្ថុតែមួយ ត្រូវអនុលោមតាមលំដាប់ពេលវេលានៃការចុះបញ្ជី លើកលែងតែមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

២- លំដាប់អាទិភាព នៃការចុះបញ្ជីបន្ថែម ត្រូវអនុលោមតាមលំដាប់ នៃការចុះបញ្ជីចម្បង ។

៣- លំដាប់អាទិភាព នៃការចុះបញ្ជីបន្ថែម ដែលស្ថិតនៅក្នុងការចុះបញ្ជីចម្បងដដែល ត្រូវអនុលោមតាមលំដាប់ពេលវេលា នៃការចុះបញ្ជីបន្ថែម។

**ប្រការ ៩ : ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី**

១- ក្នុងករណីពាក្យសុំចុះបញ្ជី ធ្វើឡើងដោយមានចំណុចខ្វះខាតដូចខាងក្រោម រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវបង្គាប់ឲ្យកែតម្រូវដោយកំណត់ពេលសមរម្យ ៖

- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- អត្តសញ្ញាណរបស់បុគ្គល ដែលមានកាតព្វកិច្ចចុះបញ្ជីនៅក្នុងពាក្យសុំចុះបញ្ជី មិនដូចគ្នានឹងសៀវភៅចុះបញ្ជី។ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបុគ្គលដាក់ពាក្យសុំចុះបញ្ជីដូចមានចែងក្នុងប្រការ ១២ (ពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ) និង ប្រការ ១៣ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែកជាអាទិ៍) នៃប្រកាសនេះ
- ពុំបានបង់ពន្ធ ឬ សោហ៊ុយសេវាផ្សេងៗ ទាក់ទងនឹងការចុះបញ្ជី

២- ក្នុងករណីបុគ្គលដាក់ពាក្យសុំចុះបញ្ជីមិនបានកែតម្រូវតាមការបង្គាប់ ដូចបានកំណត់ក្នុងចំណុចទី១ខាងលើទេ រដ្ឋបាលសុរិយោដីនោះ ត្រូវលើកពាក្យសុំចុះបញ្ជីនោះចោល ។

៣- បើពាក្យសុំចុះបញ្ជីធ្វើឡើងពុំបានត្រឹមត្រូវ ដោយមូលហេតុ នៃការដាក់ពាក្យសុំចុះបញ្ជីខុសសមត្ថកិច្ច ឬ ការចុះបញ្ជី ដែលកំពុងដាក់ពាក្យសុំនោះបានធ្វើឡើងម្តងហើយ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវលើកពាក្យសុំចុះបញ្ជីនោះចោល ។

៤- ក្រៅពីមូលហេតុដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី២ និងកថាខណ្ឌទី៣ ខាងលើនេះ ប្រសិនបើពាក្យសុំនោះមិនអនុលោមតាមលក្ខខណ្ឌ នៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនោះរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ក៏អាចលើកចោលពាក្យសុំបានដែរ ។

៥- ការលើកពាក្យសុំចោលដូចមានចែងក្នុងកថាខណ្ឌទី២ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤ ខាងលើនេះ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើលិខិតលើកចោលជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់ពីមូលហេតុ ហើយត្រូវជូនដំណឹងអំពីការលើកចោលនេះទៅបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី ឬ អ្នកតំណាង ។

៦- ចំពោះការលើកចោលពាក្យសុំខាងលើនេះ អាចធ្វើការតវ៉ាទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលបាន។ ប្រសិនបើរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលលើកចោលការតវ៉ានេះ បុគ្គលដែលដាក់ពាក្យសុំតវ៉ា អាចធ្វើការតវ៉ាទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាន ។

ចំពោះការលើកចោលក្នុងកថាខណ្ឌខាងលើនេះ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលដែលបានដាក់ពាក្យសុំតវ៉ា ។

៧- នៅពេលដែលលើកពាក្យសុំចុះបញ្ជីដោយផ្អែកលើប្រកាសនេះ រដ្ឋបាលសុរិយោដីត្រូវប្រគល់ឯកសារភ្ជាប់ទៅឲ្យអ្នកដាក់ពាក្យសុំចុះបញ្ជី ឬ អ្នកតំណាងវិញ ។

## ជំពូកទី ២
## បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ

**ប្រការ ១០ : បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ**

១-ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើឡើងរួមគ្នាដោយបុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ។

២-ចំពោះករណីដូចខាងក្រោមនេះ បុគ្គលមានសិទ្ធិចុះបញ្ជី អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

- ការផ្ទេរសិទ្ធិដោយសារសន្តតិកម្ម លើកលែងតែអច្ច័យទាន ត្រូវអនុវត្តដូចចំណុច១នៃប្រការនេះ
- ការផ្ទេរសិទ្ធិដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល
- ការលុបការចុះបញ្ជីផលុបភោគ ដោយសារមរណភាពរបស់ផលុបភោគីដើម
- សាលក្រម សាលដីកា ឬ ដីកាសម្រេច ដែលបានចូលជាស្ថាពរ ឬ លិខិតអនុវត្តដោយផ្អែកលើ ការផ្សះផ្សារ ឬ ការទទួលស្គាល់នូវការទាមទារ ដែលលិខិតអនុវត្តទាំងអស់នោះ បង្គាប់ឲ្យមាន នីតិវិធីចុះបញ្ជី
- បញ្ញត្តិក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត។

៣-បុគ្គលដែលបានទទួលការចុះបញ្ជី ជាម្ចាស់សិទ្ធិរួចហើយ អាចដាក់ពាក្យសុំផ្លាស់ប្តូរ ឬ កែតម្រូវ ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ របស់ខ្លួនតែម្នាក់ឯងបាន។

៤-ចំពោះពាក្យសុំចុះបញ្ជីដូចមានចែងក្នុងចំណុចទី១ ទី២ ទី៣ ខាងលើនេះ អាចធ្វើឡើងដោយអ្នកតំណាង បាន។

**ប្រការ ១១ : ពាក្យសុំដែលធ្វើឡើងដោយបុគ្គលទទួលបន្តជាសកល**

ក្នុងករណីដែលមានការទទួលបន្តជាសកល បុគ្គលដែលត្រូវទទួលបន្តជាសកលនោះ អាចដាក់ពាក្យសុំ ចុះបញ្ជី ក្នុងនាមជាបុគ្គលមានសិទ្ធិចុះបញ្ជី ឬ មានកាតព្វកិច្ចចុះបញ្ជីបាន។

**ប្រការ ១២ : ពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

រាល់ពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវធ្វើឡើងដោយម្ចាស់កម្ម សិទ្ធិអវិភាគទាំងអស់។

បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបកម្មសិទ្ធិអវិភាគ ។

**ប្រការ ១៣ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក ជាអាទិ៍**

១- ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក ត្រូវធ្វើឡើងរួមគ្នា ដោយម្ចាស់បំណុលហ៊ីប៉ូតែក ដែលត្រូវផ្លាស់ប្តូរលំដាប់ ។

២- បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំចុះបញ្ជី អំពីការ ផ្លាស់ប្តូរ លំដាប់ឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ។

៣- បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំចុះបញ្ជីដែលមាន ចែងក្នុងវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ៨៧៩ (សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) នៃ ក្រមរដ្ឋប្បវេណី។

# ជំពូកទី ៣
## ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ

**ប្រការ ១៤: បទប្បញ្ញត្តិទូទៅ អំពីចំណុចដែលត្រូវចុះបញ្ជី**

១– ចំណុចទូទៅ ដែលត្រូវចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ មានដូចខាងក្រោម ៖

- ឈ្មោះ ឬ នាមករណ៍របស់បុគ្គលមានសិទ្ធិចុះបញ្ជី
- គោលបំណង នៃការចុះបញ្ជី
- មូលហេតុ នៃការចុះបញ្ជី និងកាលបរិច្ឆេទ
- មូលហេតុ នៃឧបាទេសកម្ម និងកាលបរិច្ឆេទ
- ឈ្មោះរបស់ឧបាទេសិក
- ការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ជាអាទិ៍ ប្រសិនបើមាន
- ចំនួន នៃចំណែករបស់ម្ចាស់សិទ្ធិអវិភាគម្នាក់ៗ
- ការសន្យាពិសេស អំពីការរលត់សិទ្ធិ ប្រសិនបើមាន (រួមទាំងលក្ខខណ្ឌ និងការកំណត់ពេល)
- លេខរៀង នៃការចុះបញ្ជី

២– ក្រៅពីចំណុចដែលមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ មានដូចខាងក្រោម ៖

- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត របស់បុគ្គលដែលមានសិទ្ធិចុះបញ្ជី។ ចំពោះនីតិបុគ្គល គឺកាលបរិច្ឆេទ នៃការបង្កើតនីតិបុគ្គលនោះ។
- ឈ្មោះឪពុកម្តាយរបស់បុគ្គលដែលមានសិទ្ធិចុះបញ្ជី

៣– ក្រៅពីចំណុចដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិប្រាតិភោគប្រត្យក្ស មានដូចខាងក្រោម ៖

- សិទ្ធិ និងអចលនវត្ថុ ក្នុងករណីយកសិទ្ធិ និងអចលនវត្ថុមកធ្វើជាកម្មវត្ថុនៃប្រាតិភោគរួម
- សិទ្ធិលើបំណុល ដែលត្រូវបានធានាដោយការបញ្ចាំ ក្នុងករណីយកសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក ឬ ឯកសិទ្ធិ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

**ប្រការ ១៥: ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍**

ក្រៅពីចំណុចដែលមានចែងនៅក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវមានដូចខាងក្រោម ៖

- អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព
- ថ្លៃឈ្នួល
- ពេលវេលានៃការបង់ថ្លៃឈ្នួល ប្រសិនបើមាន
- ការសន្យាពិសេសដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ២៥៤ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

**ប្រការ ១៦ : ចំណុចដែលត្រូវចុះបញ្ជី អំពីផលុបភោគ**

ក្រៅពីចំណុចដែលមានចែងនៅក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីផលុបភោគ ត្រូវមានដូចខាងក្រោម ៖

- គោលបំណងផលុបភោគ
- អំឡុងពេល ឬ ហេតុណាមួយដែលបានកំណត់ នៃផលុបភោគ
- តម្លៃថ្នូរនៃផលុបភោគ ប្រសិនបើមាន
- ពេលវេលានៃការបង់តម្លៃថ្នូរ ប្រសិនបើមាន
- ការសន្យាពិសេសដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ២៦៩ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

**ប្រការ ១៧ : ចំណុចដែលត្រូវចុះបញ្ជី អំពីសេវភាព**

១- ក្រៅពីចំណុចដែលមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីសេវភាពនៃដីបម្រើ ត្រូវមានដូចខាងក្រោម ៖

- អត្តសញ្ញាណដីប្រើ
- គោលបំណងសេវភាព
- អំឡុងពេលដែលសេវភាពមានអត្ថិភាព
- ទំហំសេវភាព
- តម្លៃថ្នូរនៃសេវភាព ប្រសិនបើមាន
- ពេលវេលានៃការបង់តម្លៃថ្នូរ ប្រសិនបើមាន
- ការសន្យាពិសេស ដូចមានចែងនៅក្នុងមាត្រា ២៨៨ ឬ កថាខណ្ឌទី១ នៃមាត្រា ២៨៩ ឬ កថាខណ្ឌទី២ នៃមាត្រា ២៩៣ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន
- ករណីម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬម្ចាស់ផលុបភោគបង្កើតសេវភាព គឺអត្តសញ្ញាណ នៃសិទ្ធិទាំងនេះ

២- ទោះបីមានបញ្ញត្តិប្រការ ១៤ ក៏ដោយ ក៏ពុំចាំបាច់ត្រូវចុះបញ្ជីពីឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែល មានសិទ្ធិចុះបញ្ជីដែរ។

៣- ចំណុចដែលត្រូវចុះបញ្ជី អំពីសេវភាពដីប្រើ ត្រូវមានដូចខាងក្រោម ៖

- អត្តសញ្ញាណដីបម្រើ
- គោលបំណងសេវភាព
- ទំហំសេវភាព
- កាលបរិច្ឆេទចុះបញ្ជីសេវភាពដីបម្រើ

**ប្រការ ១៨ : ចំណុចដែលត្រូវចុះបញ្ជី អំពីឯកសិទ្ធិ**

១- ក្រៅពីចំណុចដែលមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីឯកសិទ្ធិ ត្រូវមានដូចខាងក្រោម ៖

- ឈ្មោះកូនបំណុល
- ចំនួនទឹកប្រាក់សិទ្ធិលើបំណុល

២- ក្រៅពីកថាខណ្ឌទី១ ខាងលើនេះ ចំណុចដែលត្រូវចុះបញ្ជី អំពីឯកសិទ្ធិចំពោះការលក់អចលនវត្ថុ ត្រូវមានដូចខាងក្រោម ៖

- ការប្រាក់ ប្រសិនបើមាន
- សំណងការខូចខាត ប្រសិនបើមាន

**ប្រការ ១៩ : ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ**

ក្រៅពីចំណុចដែលមានចែងនៅក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ ត្រូវមានដូចខាងក្រោម ៖

- ឈ្មោះកូនបំណុល
- អំឡុងពេល ប្រសិនបើមាន
- ចំនួនប្រាក់ដើម
- ប្រាក់ធានាសង ប្រសិនបើមាន
- ការសន្យាពិសេសដូចមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា ៨២០ ឬ មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ប្រសិនបើមាន

**ប្រការ ២០ : ចំណុចដែលត្រូវចុះបញ្ជី អំពីហ៊ីប៉ូតែក**

ក្រៅពីចំណុចដែលមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីហ៊ីប៉ូតែក ត្រូវមានដូចខាងក្រោម ៖

- ឈ្មោះកូនបំណុល
- ចំនួនប្រាក់ដើម
- ការប្រាក់ ប្រសិនបើមាន
- សំណងការខូចខាត ប្រសិនបើមាន
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ប្រសិនបើមាន

**ប្រការ ២១ : ចំណុចដែលត្រូវចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

ក្រៅពីចំណុចដែលមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវមានដូចខាងក្រោម ៖

- ឈ្មោះកូនបំណុល
- ចំនួនទឹកប្រាក់អតិបរមា
- ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា (ប្រភេទ នៃប្រតិបត្តិការដែលបង្កើតសិទ្ធិលើបំណុលដែលត្រូវបានធានា)
- កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ដូចមានចែងក្នុងមាត្រា ៨៧១ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន
- ការសន្យាពិសេស ដូចមានចែងក្នុងវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា ៨៧៩ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន។

**ប្រការ ២២ : ចំណុចដែលត្រូវចុះបញ្ជី អំពីការសន្យាពិសេស នៃការលោះ**

ក្រៅពីចំណុចដែលមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ ត្រូវមានដូចខាងក្រោម ៖

- ថ្លៃលក់

- សោហ៊ុយក្នុងការធ្វើកិច្ចសន្យា
- អំឡុងពេលនៃការលោះ

**ប្រការ ២៣ : ចំណុចដែលត្រូវចុះបញ្ជី អំពីការផ្ទេរសិទ្ធិប្រាតិភោគប្រត្យក្ស តាមការធ្វើអនុប្បទានមួយភាគ ជាអាទិ៍នៃសិទ្ធិលើបំណុល ដែលត្រូវបានធានា**

ករណីធ្វើអនុប្បទានមួយភាគ ឬ ឧបាទេសកម្មដោយការសងមួយភាគ នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ក្រៅពីចំណុចដូចមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីការផ្ទេរមួយភាគនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក គឺចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល ដែលធ្វើអនុប្បទាន ឬ ឧបាទេសកម្មដោយការសងនោះ ។

**ប្រការ ២៤ : ចំណុចដែលត្រូវចុះបញ្ជី អំពីការចាត់ចែងសិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក**

បញ្ញត្តិប្រការ ១៩ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត ឬ ការធ្វើអនុប្បទាន ឬ ការបោះបង់សិទ្ធិលើការបញ្ចាំ ។

បញ្ញត្តិប្រការ ២០ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត ឬ អនុប្បទាន ឬ ការបោះបង់ហ៊ីប៉ូតែក ។

**ប្រការ ២៥ : ចំណុចដែលត្រូវចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម**

ក្រៅពីចំណុចដូចមានចែងក្នុងប្រការ ២០ ចំណុចដែលត្រូវចុះបញ្ជី អំពីឧបាទេសកម្ម ដោយផ្អែកលើមាត្រា ៨៥៨ នៃក្រមរដ្ឋប្បវេណី ត្រូវមានដូចខាងក្រោម ៖

- អត្តសញ្ញាណអចលនវត្ថុដែលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់លើគេទទួលបានពីការសង
- ថ្លៃលក់អចលនវត្ថុ
- ចំនួនប្រាក់សងដែលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់លើគេទទួលបាន
- អត្តសញ្ញាណសិទ្ធិលើបំណុលដែលត្រូវបានធានាដោយប្រាតិភោគ

## ជំពូកទី ៤
## ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ
### ផ្នែកទី ១
### ទម្រង់ និងឯកសារភ្ជាប់ពាក្យសុំចុះបញ្ជី

**ប្រការ ២៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី**

ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវសរសេរនូវចំណុចដូចខាងក្រោម និងទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ ៖

- ឈ្មោះប្រទេសជាផ្លូវការ
- បាវចនា
- រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ
- គោលបំណងនៃពាក្យសុំចុះបញ្ជី

- មូលហេតុនៃពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ នៅពេលសាមីខ្លួនមិនមែនជាបុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះរបស់អភិបាលតំណាងនីតិបុគ្គល នៅពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជានីតិបុគ្គល
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ក្នុងករណីការដាក់ពាក្យសុំចុះបញ្ជីត្រូវបានធ្វើឡើងដោយអ្នកតំណាង
- អត្តសញ្ញាណ នៃអចលនវត្ថុ
- កិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ជាអាទិ៍ ប្រសិនបើមាន
- មូលហេតុ ដែលនាំឲ្យមានឧបាទេសកម្ម និងកាលបរិច្ឆេទនៃមូលហេតុនោះ នៅពេលដែលអ្នកដាក់ពាក្យសុំ គឺជាឧបាទេសិក
- ឈ្មោះ និងអាសយដ្ឋានរបស់ឧបាទេសិក ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក
- ឈ្មោះរបស់មតកជន ឬ របស់នីតិបុគ្គលដែលត្រូវបានរួមបញ្ចូល នៅពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជាបុគ្គលទទួលបន្តជាសកល
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ ហត្ថលេខា ឬ ស្នាមម្រាមដៃរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី
- ចំណែករបស់ម្ចាស់សិទ្ធិម្នាក់ៗ ក្នុងករណីដែលមានម្ចាស់សិទ្ធិពីរ ឬ ច្រើននាក់
- ឯកសារភ្ជាប់

**ប្រការ ២៧ : បទប្បញ្ញត្តិទូទៅចំពោះឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី**

នៅពេលដាក់ពាក្យសុំចុះបញ្ជី បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនដូចខាងក្រោម ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ ៖

- ឯកសារដែលបញ្ជាក់ អំពីអត្តសញ្ញាណរបស់បុគ្គល ដែលដាក់ពាក្យសុំចុះបញ្ជី
- លិខិតបញ្ជាក់សិទ្ធិតំណាងរបស់អភិបាលតំណាងនីតិបុគ្គល ប្រសិនបើអ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល
- ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីនោះ ជាជនដែលស្ថិតនៅក្រោមអ្នកតំណាង ដែលកំណត់ដោយច្បាប់
- លិខិតប្រគល់សិទ្ធិតំណាង ក្នុងករណីដែលពាក្យសុំធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ
- ឯកសារបញ្ជាក់អំពីមូលហេតុ នៃការចុះបញ្ជី
- ឯកសារបញ្ជាក់អំពីមូលហេតុ នៃឧបាទេសកម្ម ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក
- សាលក្រម ឬ សាលដីកាស្ថាពរ ជាអាទិ៍ ក្នុងករណីដែលពាក្យសុំចុះបញ្ជី ត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ ជាអាទិ៍
- ឯកសារបញ្ជាក់ពីការយល់ព្រមរបស់តតិយជន ក្នុងករណីពាក់ព័ន្ធផលប្រយោជន៍តតិយជននោះ
- ឯកសារបញ្ជាក់អំពីសន្តតិកម្ម ឬ ការរួមបញ្ចូលគ្នានៃនីតិបុគ្គល ក្នុងករណីពាក្យសុំចុះបញ្ជី ដែលមានចែងក្នុងកថាខណ្ឌទី ២ ប្រការ ១០ និង ប្រការ ១១ នៃប្រកាសនេះ
- គំនូសបង្ហាញសេវភាព
- គំនូសបង្ហាញទីតាំងអាគារ ដែលជាកម្មវត្ថុនៃផលុបភោគ

- ប័ណ្ណ
- ឯកសារពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ផ្នែកទី ២
## ពាក្យសុំចុះបញ្ជី អំពីកម្មសិទ្ធិ

**ប្រការ ២៨ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ**

នៅពេលកម្មសិទ្ធិ ត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរកម្មសិទ្ធិទាំងមូល
- ការផ្ទេរកម្មសិទ្ធិមួយផ្នែក

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលក់ទិញ
- ប្រទានកម្ម
- ការដូរ
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មី

ង- អត្តសញ្ញាណ នៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ២៩ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ**

នៅពេលចំណែកកម្មសិទ្ធិអវិភាគ ត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគទាំងមូលរបស់ម្ចាស់កម្មសិទ្ធិអវិភាគ ឈ្មោះ.........នៃលេខ...... ឬ
- ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយផ្នែករបស់ម្ចាស់កម្មសិទ្ធិអវិភាគ ឈ្មោះ.........នៃលេខ......

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលក់ទិញ
- ប្រទានកម្ម
- ការដូរ
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- ការបែងចែកកម្មសិទ្ធិអវិភាគ
- ការបោះបង់ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគ ឬ
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៣០ : ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ

នៅពេលកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថា មានកំហុស ឬ ខកខានមិនបានចុះបញ្ជី ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖
- ការកែតម្រូវកម្មសិទ្ធិ ឬ
- ការកែតម្រូវចំណែកកម្មសិទ្ធិអវិភាគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖
- មានកំហុស ឬ
- ការខកខានមិនបានចុះបញ្ជី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវកែតម្រូវណាមួយដូចខាងក្រោម ៖
- គោលបំណង
- ចំណែក
- ឈ្មោះម្ចាស់កម្មសិទ្ធិ ឬ កម្មសិទ្ធិអវិភាគ

ង- អត្តសញ្ញាណនៃអចលនវត្ថុ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៣១ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ

នៅពេលការផ្ទេរកម្មសិទ្ធិត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖
- ការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ

- ការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិមួយផ្នែក
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគទាំងមូល
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយផ្នែក

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- អត្តសញ្ញាណ នៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៣
## ពាក្យសុំចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍

**ប្រការ ៣២ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍**

នៅពេលបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ការបង្កើត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ

- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី ៖

- ចំណែករបស់អ្នកជួលអចិន្ត្រៃយ៍
- អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព
- ថ្លៃឈ្នួលសិទ្ធិជួលអចិន្ត្រៃយ៍
- ពេលវេលានៃការបង់ថ្លៃឈ្នួល
- ការសន្យាពិសេសដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ២៥៤ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន ។

ង– អត្តសញ្ញាណ នៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៣៣ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍**

នៅពេលសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍នៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍មួយផ្នែក

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលក់ទិញ
- ប្រទានកម្ម
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់អ្នកជួលអចិន្ត្រៃយ៍

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៣៤ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ**

នៅពេលចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគទាំងមូល របស់ឈ្មោះ.................
- ការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគមួយផ្នែក របស់ឈ្មោះ................

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលក់ទិញ
- ប្រទានកម្ម
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- ការបែងចែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ
- ការបោះបង់ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត

- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៣៥ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បន្ត**

នៅពេលសិទ្ធិជួលអចិន្ត្រៃយ៍បន្តត្រូវបានបង្កើត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណង

- ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បន្ត

ខ– មូលហេតុ និងកាលបរិច្ឆេទ

- ការបង្កើត

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែក
- អំឡុងពេលសិទ្ធិជួលអចិន្ត្រៃយ៍បន្ត
- ថ្លៃឈ្នួលសិទ្ធិជួលអចិន្ត្រៃយ៍បន្ត

- ពេលវេលានៃការបង់ថ្លៃឈ្នួល
- ការសន្យាពិសេសដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ២៥៤ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៣៦ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេល ថ្លៃឈ្នួល ពេលវេលានៃការបង់ថ្លៃឈ្នួល ឬ ការសន្យាពិសេស អំពីសិទ្ធិជួលអចិន្ត្រៃយ៍**

នៅពេលមានការផ្លាស់ប្តូរ ឬ កែតម្រូវអំឡុងពេល ថ្លៃឈ្នួល ពេលវេលានៃការបង់ថ្លៃឈ្នួល ឬ ការសន្យាពិសេស អំពីសិទ្ធិជួលអចិន្ត្រៃយ៍ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរ ឬ កែតម្រូវអំឡុងពេលសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្លាស់ប្តូរ ឬ កែតម្រូវថ្លៃឈ្នួលសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្លាស់ប្តូរ ឬ កែតម្រូវពេលវេលានៃការបង់ថ្លៃឈ្នួលសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្លាស់ប្តូរ ឬ កែតម្រូវការសន្យាពិសេសអំពីសិទ្ធិជួលអចិន្ត្រៃយ៍

ខ- មូលហេតុណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរ និងកាលបរិច្ឆេទ
- កំហុស
- ការខកខានមិនបានចុះបញ្ជី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ ឬ កែតម្រូវណាមួយដូចខាងក្រោម ៖

- អំឡុងពេល
- ថ្លៃឈ្នួល
- ពេលវេលានៃការបង់ថ្លៃឈ្នួល ឬ

- ការសន្យាពិសេសដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ២៥៤ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៣៧ : ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍**

នៅពេលសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថា មានកំហុស ឬ ខកខានមិនបានចុះបញ្ជី ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការកែតម្រូវសិទ្ធិជួលអចិន្ត្រៃយ៍
- ការកែតម្រូវចំណែកសិទ្ធិជួលអចិន្ត្រៃយ៍

ខ- មូលហេតុណាមួយដូចខាងក្រោម៖

- កំហុស
- ការខកខានមិនបានចុះបញ្ជី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវកែតម្រូវណាមួយដូចខាងក្រោម ៖

- គោលបំណង
- ចំណែក
- ឈ្មោះអ្នកជួលអចិន្ត្រៃយ៍

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬលេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៣៨ :    ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍**

នៅពេលសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះ អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការលុបការចុះបញ្ជី អំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍
- ការលុបការចុះបញ្ជី អំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍
- ការលុបការចុះបញ្ជី អំពីការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍មួយផ្នែក
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគទាំងមូល
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគមួយផ្នែក

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការផុតអំឡុងពេល
- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

-បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

# ផ្នែកទី ៤
# ពាក្យសុំចុះបញ្ជី អំពីផលុបភោគ

**ប្រការ ៣៩ :	ពាក្យសុំចុះបញ្ជី អំពីការបង្កើតផលុបភោគ**

នៅពេលបង្កើតផលុបភោគ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការបង្កើតផលុបភោគលើដី
- ការបង្កើតផលុបភោគលើអគារ
- ការបង្កើតផលុបភោគលើដី និងអគារ

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ការបង្កើត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

-បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់ផលុបភោគី
- អំឡុងពេលដែលផលុបភោគមានអត្ថិភាព ឬ លក្ខខណ្ឌ ឬ ព្រឹត្តិការណ៍ ប្រសិនបើមាន
- តម្លៃថ្នូរ នៃផលុបភោគ
- ពេលវេលានៃការបង់តម្លៃថ្នូរ
- ការសន្យាពិសេសដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ២៦៩ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខបណ្ណ
- គំនូសបង្ហាញទីតាំងអគារ
- លេខវិញ្ញាបនបត្រសម្គាល់ផលុបភោគ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤០ :   ពាក្យសុំចុះបញ្ជី អំពីការផ្ទេរផលុបភោគ**

នៅពេលផលុបភោគត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរផលុបភោគ
- ការផ្ទេរផលុបភោគមួយផ្នែក

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលក់ទិញ
- ប្រទានកម្ម
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

-បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់ផលុបភោគី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់ផលុបភោគ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤១ :   ពាក្យសុំចុះបញ្ជី អំពីការផ្ទេរចំណែកផលុបភោគអវិភាគ**

នៅពេលចំណែកផលុបភោគត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

– ការផ្ទេរចំណែកផលុបភោគអវិភាគទាំងមូលរបស់ឈ្មោះ..................
– ការផ្ទេរចំណែកផលុបភោគអវិភាគមួយផ្នែករបស់ឈ្មោះ..................

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖
– ការលក់ទិញ
– ប្រទានកម្ម
– សន្តតិកម្ម
– ការបែងចែងមត៌កតាមការព្រមព្រៀង
– អច្ច័យទាន
– សាលក្រម ឬ សាលដីកាស្ថាពរ
– ការបែងចែកផលុបភោគអវិភាគ
– ការបោះបង់ចំណែកផលុបភោគ
– មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ– បុគ្គលមានសិទ្ធិចុះបញ្ជី
– ឈ្មោះ
– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
– អាសយដ្ឋាន
– ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
– ឈ្មោះ
– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
– អាសយដ្ឋាន
– ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី
– ចំណែកផលុបភោគ

ង– អត្តសញ្ញាណនៃអចលនវត្ថុ
– ទីតាំងដី
– លេខក្បាលដី ឬ លេខប័ណ្ណ
– លេខវិញ្ញាបនបត្រសម្គាល់ផលុបភោគ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤២ : ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវអំឡុងពេល តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ ការសន្យាពិសេសអំពីផលុបភោគ**

នៅពេលមានការផ្លាស់ប្តូរ ឬ កែតម្រូវអំឡុងពេល តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ ការសន្យាពិសេសអំពីផលុបភោគ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរ ឬ កែតម្រូវអំឡុងពេលផលុបភោគ
- ការផ្លាស់ប្តូរ ឬ កែតម្រូវតម្លៃថ្នូរផលុបភោគ
- ការផ្លាស់ប្តូរ ឬ កែតម្រូវពេលវេលានៃការបង់តម្លៃថ្នូរផលុបភោគ
- ការផ្លាស់ប្តូរ ឬ កែតម្រូវការសន្យាពិសេសអំពីផលុបភោគ

ខ- មូលហេតុណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរ និងកាលបរិច្ឆេទ
- កំហុស
- ការខកខានមិនបានចុះបញ្ជី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ ឬ កែតម្រូវណាមួយដូចខាងក្រោម ៖

- អំឡុងពេល
- តម្លៃថ្នូរ
- ពេលវេលានៃការបង់តម្លៃថ្នូរ
- ការសន្យាពិសេសដែលមានចែងនៅក្នុងកថាខណ្ឌទី៣ មាត្រា ២៦៩ នៃក្រមរដ្ឋប្បវេណី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់ផលុបភោគ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤៣ : ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវផលុបភោគ ឬ ចំណែកផលុបភោគ**

នៅពេលផលុបភោគ ឬ ចំណែកផលុបភោគត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការកែតម្រូវផលុបភោគ
- ការកែតម្រូវចំណែកផលុបភោគ

ខ- មូលហេតុណាមួយដូចខាងក្រោម ៖

- កំហុស
- ការខកខានមិនបានចុះបញ្ជី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចដែលត្រូវកែតម្រូវណាមួយដូចខាងក្រោម ៖

- គោលបំណង
- ចំណែក
- ឈ្មោះរបស់ផលុបភោគី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់ផលុបភោគ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤៤ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីផលុបភោគ**

នៅពេលផលុបភោគត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការលុបការចុះបញ្ជី អំពីការបង្កើតផលុបភោគ
- ការលុបការចុះបញ្ជី អំពីការផ្ទេរផលុបភោគ
- ការលុបការចុះបញ្ជី អំពីការផ្ទេរផលុបភោគមួយផ្នែក
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកផលុបភោគអវិភាគទាំងមូល
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកផលុបភោគអវិភាគមួយផ្នែក

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- មរណភាពរបស់ផលុបភោគីដើម

- ការផុតអំឡុងពេល
- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬលេខប័ណ្ណ
- លេខវិញ្ញាបនបត្រសម្គាល់ផលុបភោគ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៥
## ពាក្យសុំចុះបញ្ជី អំពីសេវភាព

### ប្រការ ៤៥ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតសេវភាព

នៅពេលបង្កើតសេវភាព ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- ការបង្កើតសេវភាព

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ការបង្កើត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី
- គោលបំណងសេវភាព
- អំឡុងពេលសេវភាព
- ទំហំសេវភាព
- តម្លៃថ្នូរចំពោះសេវភាព ប្រសិនបើមាន
- ពេលវេលានៃការបង់តម្លៃថ្នូរសេវភាព
- ការសន្យាពិសេស ដូចមានចែងនៅក្នុងមាត្រា ២៨៨ ឬ កថាខណ្ឌទី១ នៃមាត្រា ២៨៩ ឬ/និង កថាខណ្ឌទី២ មាត្រា ២៩៣ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

ង– អត្តសញ្ញាណនៃអចលនវត្ថុ

អត្តសញ្ញាណដីប្រើ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

អត្តសញ្ញាណដីបម្រើ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

### ប្រការ ៤៦ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្ដូរ ឬ កែតម្រូវអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់ថ្លៃថ្នូរ ឬ ការសន្យាពិសេសអំពីសេវភាព

នៅពេលមានការផ្លាស់ប្ដូរ ឬ កែតម្រូវអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ ការសន្យាពិសេស អំពីសេវភាព ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖
- ការផ្លាស់ប្ដូរ ឬ កែតម្រូវអំឡុងពេលសេវភាព
- ការផ្លាស់ប្ដូរ ឬ កែតម្រូវគោលបំណងសេវភាព
- ការផ្លាស់ប្ដូរ ឬ កែតម្រូវទំហំសេវភាព
- ការផ្លាស់ប្ដូរ ឬ កែតម្រូវតម្លៃថ្នូរសេវភាព
- ការផ្លាស់ប្ដូរ ឬ កែតម្រូវពេលវេលានៃការបង់តម្លៃថ្នូរសេវភាព
- ការផ្លាស់ប្ដូរ ឬ កែតម្រូវការសន្យាពិសេសអំពីសេវភាព

ខ– មូលហេតុណាមួយដូចខាងក្រោម ៖
- ការផ្លាស់ប្ដូរ និងកាលបរិច្ឆេទ

- កំហុស
- ការខកខានមិនបានចុះបញ្ជី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវផ្លាស់ប្តូរ
- អំឡុងពេល
- គោលបំណងសេវភាព
- ទំហំសេវភាព
- តម្លៃថ្នូរ
- ពេលវេលា នៃការបង់តម្លៃថ្នូរ
- ការសន្យាពិសេស ដូចមានចែងនៅក្នុងមាត្រា ២៨៨ ឬ កថាខណ្ឌទី១ នៃមាត្រា ២៨៩ ឬ/និង កថាខណ្ឌទី២ មាត្រា ២៩៣ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមាន

ង- អត្តសញ្ញាណនៃអចលនវត្ថុ

អត្តសញ្ញាណដីបម្រើ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

អត្តសញ្ញាណដីប្រើ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤៧ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសេវភាព**

នៅពេលសេវភាពត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជន ដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះ អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង
- ការលុបការចុះបញ្ជី អំពីការបង្កើតសេវភាព

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖
- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងដែលមានចែងក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

អត្តសញ្ញាណដីបម្រើ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

អត្តសញ្ញាណដីប្រើ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៦
## ពាក្យសុំចុះបញ្ជី អំពីឯកសិទ្ធិ

### ប្រការ ៤៨ : ពាក្យសុំចុះបញ្ជី អំពីឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ

នៅពេលបង្កើតឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖
- ឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ
- ឯកសិទ្ធិសម្រាប់ការងារលើអចលនវត្ថុ
- ឯកសិទ្ធិសម្រាប់ការលក់អចលនវត្ថុ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការរក្សាទុកនូវអចលនវត្ថុ
- ការងាររលើអចលនវត្ថុ
- ការលក់អចលនវត្ថុ
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ឈ្មោះកូនបំណុល
- ចំនួនទឹកប្រាក់សិទ្ធិលើបំណុល
- ការប្រាក់ ចំពោះការលក់អចលនវត្ថុ តាមមាត្រា ៨០២ នៃក្រមរដ្ឋប្បវេណី
- សំណងការខូចខាត ប្រសិនបើមាន

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៤៩ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរឯកសិទ្ធិ**

នៅពេលឯកសិទ្ធិត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរឯកសិទ្ធិ លេខ..................
- ការផ្ទេរឯកសិទ្ធិមួយផ្នែក លេខ.................

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- អនុប្បទានសិទ្ធិលើបំណុល
- អនុប្បទានសិទ្ធិលើបំណុលមួយផ្នែក
- ឧបាទេសកម្មដោយការសង
- ឧបាទេសកម្មដោយការសងមួយផ្នែក

- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំនួនទឹកប្រាក់សិទ្ធិលើបំណុលដែលបានធ្វើអនុប្បទាន
- ចំនួនទឹកប្រាក់ដែលបានសង
- ចំណែក

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៥០ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីឯកសិទ្ធិ

នៅពេលឯកសិទ្ធិត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជន ដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណង

- ការលុបការចុះបញ្ជី អំពីឯកសិទ្ធិ លេខ..........

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការសង
- ការបោះបង់ឯកសិទ្ធិ
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
  - ឈ្មោះ
  - ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
  - អាសយដ្ឋាន
  - ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ
  - ទីតាំងដី
  - លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៧
## ពាក្យសុំចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ

**ប្រការ ៥១ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ**

នៅពេលបង្កើតសិទ្ធិលើការបញ្ចាំ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖
  - ការបង្កើតសិទ្ធិលើការបញ្ចាំកម្មសិទ្ធិ
  - ការបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិជួលអចិន្ត្រៃយ៍
  - ការបង្កើតសិទ្ធិលើការបញ្ចាំផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទ ៖

ខ-១ – កិច្ចសន្យាខ្ចីបរិភោគ
  – មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត

ខ-២ – កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ

គ- បុគ្គលមានសិទ្ធិចុះបញ្ជី
  - ឈ្មោះ
  - ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
  - អាសយដ្ឋាន
  - ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
  - ឈ្មោះ
  - ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
  - អាសយដ្ឋាន
  - ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី ៖
  - ឈ្មោះកូនបំណុល

- អំឡុងពេលដែលមានអត្ថិភាព
- ចំនួនប្រាក់ដើម
- ប្រាក់ធានាសង
- ការសន្យាពិសេសដូចមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា ៨២០ ឬ មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណី
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខបណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៥២ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ**

នៅពេលសិទ្ធិលើការបញ្ចាំត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ទម្រង់ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរសិទ្ធិលើការបញ្ចាំកម្មសិទ្ធិ លេខ...........
- ការផ្ទេរសិទ្ធិលើការបញ្ចាំមួយផ្នែកលើកម្មសិទ្ធិ លេខ...........
- ការផ្ទេរសិទ្ធិលើការបញ្ចាំសិទ្ធិជួលអចិន្ត្រៃយ៍ លេខ............
- ការផ្ទេរសិទ្ធិលើការបញ្ចាំមួយផ្នែកលើសិទ្ធិជួលអចិន្ត្រៃយ៍ លេខ.............
- ការផ្ទេរសិទ្ធិលើការបញ្ចាំផលុបភោគ លេខ...........
- ការផ្ទេរសិទ្ធិលើការបញ្ចាំមួយផ្នែកលើផលុបភោគ លេខ..........

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- អនុប្បទានសិទ្ធិលើបំណុល
- អនុប្បទានសិទ្ធិលើបំណុលមួយផ្នែក
- ឧបាទេសកម្មដោយការសង
- ឧបាទេសកម្មដោយការសងមួយផ្នែក
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន

- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀត ដែលត្រូវចុះបញ្ជី

- ចំនួនទឹកប្រាក់សិទ្ធិលើបំណុល ដែលត្រូវបានធ្វើអនុប្បទាន
- ចំនួនទឹកប្រាក់ នៃការសង
- ចំណែកសិទ្ធិលើការបញ្ចាំ

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៥៣ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត**

នៅពេលបង្កើតសិទ្ធិលើការបញ្ចាំបន្ត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- ការបង្កើតសិទ្ធិលើការបញ្ចាំបន្តលើការបញ្ចាំលេខ..........

ខ- មូលហេតុ និងកាលបរិច្ឆេទ

ខ-១ – កិច្ចសន្យាខ្ចីបរិភោគ

– មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

ខ-២ – កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំបន្ត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ឈ្មោះកូនបំណុល
- អំឡុងពេល
- ចំនួនប្រាក់ដើម
- ប្រាក់ធានាសង
- ការសន្យាពិសេសដូចមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា ៨២០ ឬ មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណី

- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៥៤ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវសិទ្ធិលើការបញ្ចាំ**

នៅពេលមានការផ្លាស់ប្តូរ ឬ កែតម្រូវចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ ការសន្យាពិសេសអំពីការបញ្ចាំ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរ ឬ កែតម្រូវចំនួនប្រាក់ដើមលើការបញ្ចាំ លេខ...........
- ការផ្លាស់ប្តូរ ឬ កែតម្រូវប្រាក់ធានាសងលើការបញ្ចាំ លេខ.........
- ការផ្លាស់ប្តូរ ឬ កែតម្រូវអំឡុងពេលលើការបញ្ចាំ លេខ.........
- ការផ្លាស់ប្តូរ ឬ កែតម្រូវលក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានាលើការបញ្ចាំ លេខ.....
- ការផ្លាស់ប្តូរ ឬ កែតម្រូវការសន្យាពិសេស អំពីការបញ្ចាំ លេខ..........

ខ- មូលហេតុណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរ និងកាលបរិច្ឆេទ
- កំហុស
- ការខកខានមិនបានចុះបញ្ជី
- មូលហេតុផ្សេងទៀត ដូចមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត និងកាលបរិច្ឆេទ

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ ឬ កែតម្រូវណាមួយ ដូចខាងក្រោម

- ចំនួនប្រាក់ដើម
- ប្រាក់ធានាសង
- អំឡុងពេល

- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុល ដែលត្រូវបានធានា
- ការសន្យាពិសេស ដូចមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា ៨២០ និង មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៩៥ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ**

នៅពេលសិទ្ធិលើការបញ្ចាំ ត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះ អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ។

ពាក្យសុំចុះបញ្ជី នៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំកម្មសិទ្ធិ លេខ..........
- ការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំសិទ្ធិជួលអចិន្ត្រៃយ៍ លេខ..........
- ការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំផលុបភោគ លេខ..........

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការសង
- ការបោះបង់សិទ្ធិលើការបញ្ចាំ
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៨
## ពាក្យសុំចុះបញ្ជី អំពីហ៊ីប៉ូតែក

**ប្រការ ៥៦ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក**

នៅពេលបង្កើតហ៊ីប៉ូតែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការបង្កើតហ៊ីប៉ូតែកលើកម្មសិទ្ធិ
- ការបង្កើតហ៊ីប៉ូតែកលើសិទ្ធិជួលអចិន្ត្រៃយ៍
- ការបង្កើតហ៊ីប៉ូតែកលើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

ខ-១ – កិច្ចសន្យាខ្ចីបរិភោគ

– មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

ខ-២ – កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ឈ្មោះកូនបំណុល
- ចំនួនប្រាក់ដើម
- ការប្រាក់
- សំណងការខូចខាត
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៥៧ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត

នៅពេលបង្កើតហ៊ីប៉ូតែកបន្ត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណង

- ការបង្កើតហ៊ីប៉ូតែកបន្ត លើហ៊ីប៉ូតែកលេខ...........

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

ខ–១ – កិច្ចសន្យាខ្ចីបរិភោគ

– មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

ខ–២ – កិច្ចសន្យាបង្កើតហ៊ីប៉ូតែកបន្ត

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ឈ្មោះកូនបំណុល
- ចំនួនប្រាក់ដើម
- ការប្រាក់
- សំណងការខូចខាត
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៥៨ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក

នៅពេលហ៊ីប៉ូតែកត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរហ៊ីប៉ូតែកលើកម្មសិទ្ធិ លេខ...............
- ការផ្ទេរហ៊ីប៉ូតែកមួយផ្នែកលើកម្មសិទ្ធិ លេខ...............

- ការផ្ទេរហ៊ីប៉ូតែកលើសិទ្ធិជួលអចិន្ត្រៃយ៍ លេខ...............
- ការផ្ទេរហ៊ីប៉ូតែកមួយផ្នែកលើសិទ្ធិជួលអចិន្ត្រៃយ៍ លេខ............
- ការផ្ទេរហ៊ីប៉ូតែកលើផលុបភោគ លេខ.............
- ការផ្ទេរហ៊ីប៉ូតែកមួយផ្នែកលើផលុបភោគ លេខ...........

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- អនុប្បទានសិទ្ធិលើបំណុល
- អនុប្បទានសិទ្ធិលើបំណុលមួយផ្នែក
- ឧបាទេសកម្មដោយការសង
- ឧបាទេសកម្មដោយការសងមួយផ្នែក
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំនួនទឹកប្រាក់សិទ្ធិលើបំណុលដែលត្រូវបានធ្វើអនុប្បទាន
- ចំនួនទឹកប្រាក់ដែលបានសង
- ចំណែក

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៥៩ : ពាក្យសុំចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម**

នៅពេលធ្វើឧបាទេសកម្មហ៊ីប៉ូតែករួម ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- ការចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួមលេខ........

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ឧបាទេសកម្ម ដោយផ្អែកលើមាត្រា ៨៥៨ នៃក្រមរដ្ឋប្បវេណី

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

ឃ១. ខ្លឹមសារ នៃការលក់ដោយបង្វិ

- អត្តសញ្ញាណនៃអចលនវត្ថុ
- ថ្លៃលក់អចលនវត្ថុ
- ទឹកប្រាក់ ដែលបានទទួលដោយម្ចាស់បំណុលហ៊ីប៉ូតែក ដែលមានអាទិភាពខ្ពស់

ឃ២. អត្តសញ្ញាណ នៃសិទ្ធិលើបំណុល ដែលត្រូវបានធានា

- មូលហេតុ និងកាលបរិច្ឆេទ
- ឈ្មោះកូនបំណុល
- ប្រាក់ដើម
- ការប្រាក់
- សំណងការខូចខាត
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦០ : ពាក្យសុំចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក**

នៅពេលធ្វើអនុប្បទានហ៊ីប៉ូតែក ឬ ធ្វើការបោះបង់ហ៊ីប៉ូតែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- អនុប្បទានហ៊ីប៉ូតែក លេខ...............លើកម្មសិទ្ធិ
- អនុប្បទានហ៊ីប៉ូតែក លេខ...............លើសិទ្ធិជួលអចិន្ត្រៃយ៍
- អនុប្បទានហ៊ីប៉ូតែក លេខ...............លើផលុបភោគ
- បោះបង់ហ៊ីប៉ូតែក លេខ.............លើកម្មសិទ្ធិ

- បោះបង់ហ៊ីប៉ូតែក លេខ............លើសិទ្ធិជួលអចិន្ត្រៃយ៍
- បោះបង់ហ៊ីប៉ូតែក លេខ............លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

ខ-១ – កិច្ចសន្យាខ្ចីបរិភោគ

– មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

ខ-២ – អនុប្បទានហ៊ីប៉ូតែក

– ការបោះបង់ហ៊ីប៉ូតែក

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ឈ្មោះកូនបំណុល
- ចំនួនប្រាក់ដើម
- ការប្រាក់
- សំណងការខូចខាត
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុល

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦១ : ពាក្យសុំចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក**

នៅពេលធ្វើអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ធ្វើការបោះបង់លំដាប់ហ៊ីប៉ូតែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- អនុប្បទានលំដាប់ហ៊ីប៉ូតែក លេខ.......... ទៅហ៊ីប៉ូតែក លេខ............លើកម្មសិទ្ធិ
- អនុប្បទានលំដាប់ហ៊ីប៉ូតែក លេខ.......... ទៅហ៊ីប៉ូតែក លេខ............លើសិទ្ធិជួលអចិន្ត្រៃយ៍
- អនុប្បទានលំដាប់ហ៊ីប៉ូតែក លេខ.......... ទៅហ៊ីប៉ូតែក លេខ............លើផលុបភោគ
- បោះបង់លំដាប់ហ៊ីប៉ូតែក លេខ.......... ទៅហ៊ីប៉ូតែក លេខ...........លើកម្មសិទ្ធិ

- បោះបង់លំដាប់ហ៊ីប៉ូតែក លេខ.......... ទៅហ៊ីប៉ូតែក លេខ...........លើសិទ្ធិជួលអចិន្ត្រៃយ៍
- បោះបង់លំដាប់ហ៊ីប៉ូតែក លេខ.......... ទៅហ៊ីប៉ូតែក លេខ...........លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖
- អនុប្បទានលំដាប់ហ៊ីប៉ូតែក
- បោះបង់លំដាប់ហ៊ីប៉ូតែក

គ- បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦២ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្ដូរលំដាប់ហ៊ីប៉ូតែក**

នៅពេលផ្លាស់ប្ដូរលំដាប់ហ៊ីប៉ូតែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖
- ការផ្លាស់ប្ដូរលំដាប់ហ៊ីប៉ូតែក លេខ............. លេខ............លើកម្មសិទ្ធិ
- ការផ្លាស់ប្ដូរលំដាប់ហ៊ីប៉ូតែក លេខ............. លេខ............លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្លាស់ប្ដូរលំដាប់ហ៊ីប៉ូតែក លេខ............. លេខ............លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទ
- ការព្រមព្រៀង

គ- អ្នកដាក់ពាក្យសុំចុះបញ្ជី
- ឈ្មោះ (ក)
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

អ្នកដាក់ពាក្យសុំចុះបញ្ជី
- ឈ្មោះ (ខ)

- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្ដូរ

- លេខលំដាប់ថ្មីនៃហ៊ីប៉ូតែកនីមួយៗ

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខបណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦៣ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្ដូរ ឬ ការកែតម្រូវហ៊ីប៉ូតែក**

នៅពេលមានការផ្លាស់ប្ដូរ ឬ ការកែតម្រូវចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្ដូរ ឬ ការកែតម្រូវចំនួនប្រាក់ដើម នៃហ៊ីប៉ូតែក លេខ.........លើកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ
- ការផ្លាស់ប្ដូរ ឬ ការកែតម្រូវការប្រាក់ នៃហ៊ីប៉ូតែកលេខ..........លើកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ
- ការផ្លាស់ប្ដូរ ឬ ការកែតម្រូវសំណងការខូចខាតនៃហ៊ីប៉ូតែក លេខ..........លើកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ
- ការផ្លាស់ប្ដូរ ឬ ការកែតម្រូវលក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា នៃហ៊ីប៉ូតែក លេខ..........លើកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ

ខ- មូលហេតុណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្ដូរ និងកាលបរិច្ឆេទ
- កំហុស
- ការខកខានមិនបានចុះបញ្ជី
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត និងកាលបរិច្ឆេទ

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត

- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ ឬ កែតម្រូវណាមួយដូចខាងក្រោម ៖

- ចំនួនប្រាក់ដើម
- ការប្រាក់
- សំណងការខូចខាត
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦៨ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក**

នៅពេលហ៊ីប៉ូតែកត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីតតិយជននោះ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកលេខ............ លើកម្មសិទ្ធិ
- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកលេខ.......... លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកលេខ.......... លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការសង
- ការបោះបង់ហ៊ីប៉ូតែក
- ការព្រមព្រៀងរំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៩
## ពាក្យសុំចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

**ប្រការ ៦៥ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

នៅពេលបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លើកម្មសិទ្ធិ
- ការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លើផលុបភោគ
- ការបង្កើតហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត លើកម្មសិទ្ធិ
- ការបង្កើតហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការបង្កើតហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទ

- កិច្ចសន្យាបង្កើត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ឈ្មោះកូនបំណុល
- ចំនួនទឹកប្រាក់អតិបរមា
- ទំហំសិទ្ធិលើបំណុលដែលត្រូវបានធានា

- កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ដែលមានចែងនៅក្នុង កថាខណ្ឌទី ១ មាត្រា ៨៧១ នៃក្រមរដ្ឋប្បវេណី
- ការសន្យាពិសេសដែលមានចែងនៅក្នុងវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ៨៧៩ នៃ ក្រមរដ្ឋប្បវេណី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦៦ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

នៅពេលផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.......លើកម្មសិទ្ធិ
- ការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.......លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.......លើផលុបភោគ
- ការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក លេខ..........លើកម្មសិទ្ធិ
- ការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក លេខ.......លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក លេខ.......លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត
- អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦៧ : ពាក្យសុំចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

ពាក្យសុំចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា ៨៧៧ នៃក្រមរដ្ឋប្បវេណី ត្រូវមានទម្រង់ដូចបានកំណត់នៅក្នុងប្រការ ២៦ (ទម្រង់ពាក្យសុំចុះបញ្ជី) ហើយត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ..........លើកម្មសិទ្ធិ
- ការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ......លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ..........លើផលុបភោគ

ខ– មូលហេតុ និងកាលបរិច្ឆេទ

- ការបែងចែក និងអនុប្បទាន

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំនួនទឹកប្រាក់អតិបរមា នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានបែងចែក និងអនុប្បទាន
- ឈ្មោះកូនបំណុលនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម
- ទំហំសិទ្ធិលើបំណុលដែលត្រូវបានធានា នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម
- កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ដែលមានចែងនៅក្នុង កថាខណ្ឌទី១ មាត្រា ៨៧១ នៃក្រមរដ្ឋប្បវេណី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត
- ការសន្យាពិសេស ដែលមានចែងនៅក្នុងវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា ៨៧៩ នៃក្រមរដ្ឋប្បវេណី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម
- មូលហេតុនៃការបង្កើត និងកាលបរិច្ឆេទ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦៨ : ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមា ទាក់ទងនឹងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

នៅពេលផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមា ទាក់ទងនឹងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើកម្មសិទ្ធិ
- ការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ......លើផលុបភោគ

ខ– មូលហេតុ និងកាលបរិច្ឆេទ

- កិច្ចសន្យាផ្លាស់ប្តូរ

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

- ចំនួនទឹកប្រាក់អតិបរមាថ្មី

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៦៩ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

នៅពេលផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ....... លើកម្មសិទ្ធិ
- ការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

លេខ....... លើសិទ្ធិជួលអចិន្ត្រៃយ៍

- ការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ....... លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ការផ្លាស់ប្តូរ

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ

- ទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាថ្មី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧០ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

នៅពេលផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើកម្មសិទ្ធិ
- ការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើផលុបភោគ

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ការផ្លាស់ប្តូរ

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

- កាលបរិច្ឆេទ ដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរថ្មី

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧១ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត**

នៅពេលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះ អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត លេខ....... លើកម្មសិទ្ធិ
- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត លេខ....... លើសិទ្ធិជួលអចិន្ត្រៃយ៍
- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត លេខ....... លើផលុបភោគ

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការសង
- ការបោះបង់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត
- ការទាមទារឲ្យរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– អត្តសញ្ញាណនៃអចលនវត្ថុ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ១០
## ពាក្យសុំចុះបញ្ជី អំពីសិទ្ធិបន្ទាប់បន្សំមួយចំនួន ដែលពាក់ព័ន្ធទៅនឹងសិទ្ធិប្រត្យក្ស

### ប្រការ ៧២ : ពាក្យសុំចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ

នៅពេលមានការសន្យាពិសេសនៃការលោះ ពាក្យសុំចុះបញ្ជី អំពីការសន្យានោះ ត្រូវធ្វើឡើងព្រមគ្នាជាមួយ ពាក្យសុំចុះបញ្ជី អំពីការផ្ទេរ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណង
- ការសន្យាពិសេសនៃការលោះ

ខ– មូលហេតុ និងកាលបរិច្ឆេទ
- ការសន្យាពិសេសនៃការលោះ

គ– បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី
- ថ្លៃលក់
- សោហ៊ុយក្នុងការធ្វើកិច្ចសន្យា
- អំឡុងពេលនៃការលោះ

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧៣ : ពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែងអចលនវត្ថុអវិភាគ**

នៅពេលដែលម្ចាស់សិទ្ធិអវិភាគទាំងអស់ បានយល់ព្រមធ្វើកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង
- ហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ

ខ- មូលហេតុ និងកាលបរិច្ឆេទ
- កិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ

គ- អ្នកដាក់ពាក្យសុំចុះបញ្ជី
- ឈ្មោះ (ក)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

អ្នកដាក់ពាក្យសុំចុះបញ្ជី
- ឈ្មោះ (ខ)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី
- អំឡុងពេល

ង- អត្តសញ្ញាណនៃអចលនវត្ថុ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧៤ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

នៅពេលដែលម្ចាស់សិទ្ធិអវិភាគទាំងអស់ បានយល់ព្រមផ្លាស់ប្តូរអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង
- ការផ្លាស់ប្តូរអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ

ខ- មូលហេតុ និងកាលបរិច្ឆេទ
- ផ្លាស់ប្តូរអំឡុងពេល

គ- អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ (ក)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ (ខ)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ

- អំឡុងពេលថ្មី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧៥ : ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

នៅពេលកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថា មានកំហុស ឬ ការខកខានមិនបានចុះអំពីអំឡុងពេល ម្ចាស់សិទ្ធិអវិភាគទាំងអស់ ត្រូវដាក់ពាក្យសុំចុះបញ្ជី ហើយពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- កែតម្រូវអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ

ខ- មូលហេតុណាមួយដូចខាងក្រោម ៖

- មានកំហុស
- ការខកខានមិនបានចុះបញ្ជី

គ- អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ (ក)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ (ខ)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- ចំណុចដែលត្រូវកែតម្រូវ

- អំឡុងពេល

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧៦ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

នៅពេលកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវបានលុបចោល ឬ រំលាយ ឬ ផុតអំឡុងពេលកំណត់ ជាអាទិ៍ ម្ចាស់សិទ្ធិអវិភាគទាំងអស់ត្រូវដាក់ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ។

ពាក្យសុំចុះបញ្ជី នៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- ការលុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការផុតអំឡុងពេលនៃកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត

គ- អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ (ក)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ (ខ)
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

# ផ្នែកទី ១១
# ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ និង ការកែតម្រូវឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ

**ប្រការ ៧៧ : ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ**

នៅពេលមានការផ្លាស់ប្តូរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះ បញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការចុះបញ្ជី អំពីការផ្លាស់ប្តូរឈ្មោះរបស់ម្ចាស់សិទ្ធិ
- ការចុះបញ្ជី អំពីការផ្លាស់ប្តូរថ្ងៃ ខែ ឆ្នាំកំណើតរបស់ម្ចាស់សិទ្ធិ
- ការចុះបញ្ជី អំពីការផ្លាស់ប្តូរទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិ
- ការចុះបញ្ជី អំពីការផ្លាស់ប្តូរឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ផ្លាស់ប្តូរឈ្មោះរបស់ម្ចាស់សិទ្ធិ
- ផ្លាស់ប្តូរថ្ងៃ ខែ ឆ្នាំកំណើតរបស់ម្ចាស់សិទ្ធិ
- ផ្លាស់ប្តូរទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិ
- ផ្លាស់ប្តូរឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ

គ– អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

- ឈ្មោះរបស់ម្ចាស់សិទ្ធិ
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់ម្ចាស់សិទ្ធិ
- ទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិ
- ឈ្មោះឪពុក ម្តាយរបស់ម្ចាស់សិទ្ធិ

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ៧៨ : ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ**

នៅពេលសិទ្ធិប្រត្យក្ស ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ការខកខានមិនបានចុះឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការចុះបញ្ជី អំពីការកែតម្រូវឈ្មោះរបស់ម្ចាស់សិទ្ធិ
- ការចុះបញ្ជី អំពីការកែតម្រូវថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិ
- ការចុះបញ្ជី អំពីការកែតម្រូវការបង្កើតនីតិបុគ្គល
- ការចុះបញ្ជី អំពីការកែតម្រូវឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ

ខ– មូលហេតុណាមួយដូចខាងក្រោម ៖

- កំហុស
- ការខកខានមិនបានចុះបញ្ជី

គ– អ្នកដាក់ពាក្យសុំចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះរបស់ម្ចាស់សិទ្ធិ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់ម្ចាស់សិទ្ធិ
- កាលបរិច្ឆេទ នៃការបង្កើតនីតិបុគ្គល
- ឈ្មោះឪពុក ម្តាយរបស់ម្ចាស់សិទ្ធិ

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

# ជំពូកទី ៥
# ការចុះបញ្ជី
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ៧៩ : ការចុះបញ្ជីបន្ថែម**

ការចុះបញ្ជីបន្ថែមត្រូវធ្វើឡើងក្នុងករណីដូចខាងក្រោម ៖

- ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បន្ត និងការចាត់ចែងសិទ្ធិជួលអចិន្ត្រៃយ៍បន្ត
- ការផ្ទេរផលុបភោគ
- ការផ្ទេរសិទ្ធិប្រាតិភោគ
- ការចុះបញ្ជី អំពីការចាត់ចែងសិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

ការចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ ការកែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ

- ការចុះបញ្ជី អំពីឧបាទេសកម្ម ដែលមានចែងក្នុងមាត្រា ៨៥៨ នៃក្រមរដ្ឋប្បវេណី
- ការចុះបញ្ជី អំពីការព្រមព្រៀងដែលមានចែងក្នុងកថាខណ្ឌទី១ ឬ២ មាត្រា ៨៧៣ នៃក្រមរដ្ឋប្បវេណី ដែលមានទំនាក់ទំនងនឹងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានចុះបញ្ជីរួចហើយ
- ការចុះបញ្ជី អំពីការផ្លាស់ប្តូរទាក់ទងនឹងការបន្ថយចំនួនទឹកប្រាក់អតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម ក្នុងករណីបែងចែក និង អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានចែងក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ២ មាត្រា ៨៧៧ នៃក្រមរដ្ឋប្បវេណី
- ការចុះបញ្ជីទាក់ទងនឹងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៨៧៩ នៃក្រមរដ្ឋប្បវេណី ដែលមានទំនាក់ទំនងជាមួយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានចុះបញ្ជីរួចហើយ
- ការចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ នៃសិទ្ធិប្រត្យក្ស ដែលបានចុះបញ្ជីរួចហើយ
- ការចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវ ក្នុងករណីដែលគ្មានតតិយជនមានផលប្រយោជន៍ក្នុងការចុះបញ្ជី
- ការចុះបញ្ជី អំពីការផ្លាស់ប្តូរ និងកែតម្រូវ ក្នុងករណីដែលមានតតិយជនដែលមានផលប្រយោជន៍ក្នុងការចុះបញ្ជី និងបើសិនឯកសារដែលបញ្ជាក់ពីការយល់ព្រមរបស់តតិយជននោះត្រូវបានភ្ជាប់មកជាមួយ ។
- ការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ លើកលែងតែការលុបការចុះបញ្ជី។

**ប្រការ ៨០ : ការចុះបញ្ជីឈ្មោះម្ចាស់សិទ្ធិអវិភាគ និងចំណែក**

នៅពេលមានម្ចាស់សិទ្ធិលើសពីម្នាក់ ហើយមានសិទ្ធិដូចគ្នា មន្ត្រីចុះបញ្ជី ត្រូវចុះអត្តសញ្ញាណ និងចំណែករបស់ម្ចាស់សិទ្ធិនីមួយៗ ។

**ប្រការ ៨១ : តារាងឈ្មោះម្ចាស់សិទ្ធិអវិភាគ**

ក្នុងករណីដែលមានម្ចាស់សិទ្ធិលើសពីពីរនាក់ មន្ត្រីចុះបញ្ជីត្រូវចុះអត្តសញ្ញាណ និងចំណែករបស់ម្ចាស់

សិទ្ធិណាម្នាក់ នៅក្នុងសៀវភៅចុះបញ្ជី ហើយត្រូវចុះអត្តសញ្ញាណ និងចំណែករបស់ម្ចាស់សិទ្ធិផ្សេងទៀត ទៅក្នុងតារាងឈ្មោះម្ចាស់សិទ្ធិអវិភាគ ។

ក្នុងករណីដែលតារាងឈ្មោះម្ចាស់សិទ្ធិអវិភាគត្រូវបានបង្កើតឡើង មន្ត្រីចុះបញ្ជីត្រូវចុះលេខតារាងឈ្មោះម្ចាស់សិទ្ធិអវិភាគនៅក្នុងខ្ទង់ "លេខាចារឹកដោយសង្ខេប នៃលិខិតសញ្ញា ឬ សាលក្រមតុលាការ" ។

តារាងឈ្មោះម្ចាស់សិទ្ធិអវិភាគ ត្រូវតែជាផ្នែកមួយ នៃសៀវភៅចុះបញ្ជី ។

## ប្រការ ៨២: តារាងប្រាតិភោគរួម

១- ក្នុងករណីអចលនវត្ថុ ឬ/និងសិទ្ធិដែលជាកម្មវត្ថុ នៃសិទ្ធិប្រាតិភោគ មានលើសពីពីរឡើងទៅ មន្ត្រីចុះបញ្ជីត្រូវធ្វើតារាងប្រាតិភោគរួម ដែលមានចុះអំពីអចលនវត្ថុ និងសិទ្ធិទាំងនោះ ។

២- ចំណុចដែលត្រូវចុះក្នុងតារាងប្រាតិភោគរួម ៖

- ថ្ងៃ ខែ ឆ្នាំ ដែលបានធ្វើតារាងប្រាតិភោគរួម
- លេខតារាងប្រាតិភោគរួម
- អត្តសញ្ញាណ នៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ
- សញ្ញាណ នៃសិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ
- លេខរៀង នៃការចុះបញ្ជីសិទ្ធិប្រាតិភោគ

៣- ក្នុងករណីដែលសិទ្ធិប្រាតិភោគលើអចលនវត្ថុ ឬ/និងសិទ្ធិ ដែលត្រូវបានលុបចេញពីសៀវភៅចុះបញ្ជី មន្ត្រីចុះបញ្ជី ត្រូវចុះបញ្ជី អំពីការលុបការចុះបញ្ជីអចលនវត្ថុ ឬ/និងសិទ្ធិនោះ ពីតារាងប្រាតិភោគរួម ។

៤- មន្ត្រីចុះបញ្ជីត្រូវចុះលេខ នៃតារាងប្រាតិភោគរួម បន្តពីការចុះបញ្ជីសិទ្ធិប្រាតិភោគនីមួយៗ

៥- តារាងប្រាតិភោគរួម ត្រូវតែជាផ្នែកមួយ នៃសៀវភៅចុះបញ្ជី ។

## ប្រការ ៨៣ : លេខរៀង

១– នៅពេលចុះបញ្ជី អំពីសិទ្ធិ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខរៀងនៅពីមុខចំណុចដែលត្រូវចុះបញ្ជីក្នុងខ្ទង់ (column) ត្រង់ "អត្រានុកូលដ្ឋាន" ឬ ខ្ទង់ "បន្ទុកលើអចលនវត្ថុ" ឬ ខ្ទង់ "សេចក្តីផ្សេងៗ" ឬ ខ្ទង់ផ្សេងទៀត ។

២– នៅពេលចុះបញ្ជី អំពីសិទ្ធិប្រាតិភោគលើសពីមួយ ដែលមានលំដាប់ដូចគ្នា មន្ត្រីចុះបញ្ជីត្រូវប្រើលេខរៀងដូចគ្នា ហើយចុះបន្តដោយអក្ខរសញ្ញាផ្សេងគ្នា ។

៣– នៅពេលចុះបញ្ជីបន្ថែម មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀងដូចគ្នាដែលមានប្រភពពីការចុះបញ្ជីចម្បង ហើយចុះបន្តដោយលេខលំដាប់សាខា។

## ប្រការ ៨៤ : ការចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១– ទោះបីមានបញ្ញត្តិចំណុច ៤ នៃប្រការ ៧៩ (ការចុះបញ្ជីបន្ថែម) ក៏ដោយ ការចុះបញ្ជីទាក់ទងនឹងការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានចែងនៅក្នុងវាក្យខណ្ឌទី១ កថាខណ្ឌទី២ មាត្រា ៨៧៧ នៃក្រមរដ្ឋប្បវេណី ( អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ) មិនត្រូវធ្វើឡើងតាមការចុះបញ្ជីបន្ថែមឡើយ។

២–ចំពោះការចុះបញ្ជីក្នុងកថាខណ្ឌទី១ ខាងលើនេះ មន្ត្រីចុះបញ្ជី ត្រូវដាក់លេខរៀងដូចគ្នា នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលជាកម្មវត្ថុ នៃការបែងចែក។

៣-នៅពេលចុះលេខរៀងដោយផ្អែកលើកថាខណ្ឌទី ២ ខាងលើ មន្ត្រីចុះបញ្ជីត្រូវចុះអក្ខរសញ្ញាផ្សេងគ្នា បន្តពីលេខរៀង នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតពីរ ដែលត្រូវបានបែងចែកនោះ ។

**ប្រការ ៨៥ : ការចុះបញ្ជីដោយឆន្ទានុសិទ្ធិរបស់មន្ត្រីចុះបញ្ជី**

១- ក្នុងករណីការចុះបញ្ជី អំពីលទ្ធកម្មសិទ្ធិផ្អែកលើការអនុវត្តសិទ្ធិលោះ មន្ត្រីចុះបញ្ជីត្រូវលុបការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះដោយឆន្ទានុសិទ្ធិ ។

២- ក្នុងករណីការចុះបញ្ជី អំពីការបែងចែក និងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដោយផ្អែកលើវាក្យខណ្ឌទី ១ កថាខណ្ឌទី ២ មាត្រា ៨៧៧ នៃក្រមរដ្ឋប្បវេណី មន្ត្រីចុះបញ្ជីត្រូវចុះអំពីការផ្លាស់ប្តូរ ដើម្បីកាត់បន្ថយចំនួនទឹកប្រាក់អតិបរមា នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលជាកម្មវត្ថុនៃការបែងចែកនោះ ដោយឆន្ទានុសិទ្ធិ ។ ក្នុងករណីនេះ មន្ត្រីចុះបញ្ជីត្រូវបញ្ជាក់ថា មូលហេតុនៃការចុះបញ្ជី គឺជាការបែងចែកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

៣- នៅពេលធ្វើការចុះបញ្ជី អំពីការបង្កើតសេវភាពនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីបម្រើ មន្ត្រីចុះបញ្ជីត្រូវចុះបញ្ជីលើដីប្រើ នូវចំណុចដែលមានចែងក្នុងកថាខណ្ឌទី ៣ នៃប្រការ ១៧ នៃប្រកាសនេះ ដោយឆន្ទានុសិទ្ធិ ។

៤- នៅពេលចុះបញ្ជីរួច ប្រសិនបើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ដោយសារមន្ត្រីចុះបញ្ជីខ្លួនឯង មន្ត្រីចុះបញ្ជីត្រូវធ្វើការកែតម្រូវដោយឆន្ទានុសិទ្ធិ ហើយត្រូវជូនដំណឹងទៅម្ចាស់សិទ្ធិ លើកលែងតែក្នុងករណី ប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន មន្ត្រីចុះបញ្ជីអាចធ្វើការកែតម្រូវទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

៥- ក្នុងករណីមានការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងនូវសិទ្ធិប្រត្យក្សរួចហើយ ហើយក្រោយមកមានការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សពីបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជីជាកូនបំណុល ទៅឲ្យបុគ្គលដែលមានសិទ្ធិចុះបញ្ជីជាម្ចាស់បំណុល នោះមន្ត្រីចុះបញ្ជីត្រូវលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ននោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

**ប្រការ ៨៦: ការចុះបញ្ជី អំពីសេវភាព**

១- ក្រោយពីបានចុះបញ្ជី អំពីការបង្កើតសេវភាពនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី នៃដីបម្រើ មន្ត្រីចុះបញ្ជីត្រូវចុះនូវចំណុចដែលមានចែងនៅក្នុងកថាខណ្ឌទី៣ នៃប្រការ ១៧ នៃប្រកាសនេះ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីប្រើដោយគ្មានការយឺតយ៉ាវ។

២- ក្រោយពីបានចុះបញ្ជី អំពីការបង្កើតសេវភាពនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី នៃដីបម្រើ ក្នុងករណីដែលទីតាំងដីប្រើស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដីផ្សេង មន្ត្រីចុះបញ្ជីត្រូវជូនដំណឹង អំពីចំណុចដែលមានចែងនៅក្នុងកថាខណ្ឌទី៣ ប្រការ ១៧ នៃប្រកាសនេះ ទៅរដ្ឋបាលសុរិយោដីនោះ ដោយគ្មានការយឺតយ៉ាវ។

៣- ក្នុងករណីដែលមានការផ្លាស់ប្តូរ ឬ កែតម្រូវ ឬ លុបការចុះបញ្ជី អំពីចំណុចដែលត្រូវចុះបញ្ជី អំពីសេវភាពនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីបម្រើ មន្ត្រីចុះបញ្ជីត្រូវផ្លាស់ប្តូរ ឬ កែតម្រូវ ឬ លុបចំណុចដែលត្រូវចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីប្រើ ដោយគ្មានការយឺតយ៉ាវ។

៤- បញ្ញត្តិដែលបានចែងនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដីប្រើមានទីតាំងស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដីផ្សេង។

៥- មន្ត្រីចុះបញ្ជីដែលបានទទួលការជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌទី២ និងទី៤ ខាងលើនេះ ត្រូវចុះបញ្ជី អំពីខ្លឹមសារនៃការជូនដំណឹងនោះ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីប្រើដោយគ្មានការយឺតយ៉ាវ។

**ប្រការ ៨៧ : គំនូសបង្ហាញទីតាំងសេវភាព**

គំនូសបង្ហាញទីតាំងសេវភាពត្រូវបញ្ជាក់អំពី ទំហំសេវភាព ទិស មាត្រដ្ឋាន លេខក្បាលដីប្រើ លេខក្បាលដីបម្រើ លេខក្បាលដីជាប់ព្រំ និងឈ្មោះរបស់អ្នកដាក់ពាក្យសុំ ។

គំនូសបង្ហាញទីតាំងសេវភាព ត្រូវតែមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សេវភាព ។

**ប្រការ ៨៨ : ការដកពាក្យសុំចុះបញ្ជី**

១- ការដកពាក្យសុំចុះបញ្ជី ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុរិយោដីមានសមត្ថកិច្ច។

២- ក្នុងករណីដកពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវប្រគល់ពាក្យសុំចុះបញ្ជីនោះ និងឯកសារភ្ជាប់ទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាង។

៣- ការដកពាក្យសុំចុះបញ្ជីដែលមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវធ្វើឡើងដោយអ្នកដាក់ពាក្យសុំចុះបញ្ជី ។ ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីមានចំនួនច្រើននាក់ ការដកពាក្យសុំចុះបញ្ជីត្រូវធ្វើឡើងដោយអ្នកដាក់ពាក្យសុំចុះបញ្ជីទាំងអស់នោះ ។

## ផ្នែកទី ២
## របៀបទូទៅ នៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្ស

**ប្រការ ៨៩: របៀបទូទៅ នៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្ស**

១. ការចុះបញ្ជី អំពីការផ្ទេរ ការផ្លាស់ប្តូរ ការកែតម្រូវ និងការលុបការចុះបញ្ជី អំពីកម្មសិទ្ធិ ត្រូវធ្វើឡើងនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

២. ការចុះបញ្ជី អំពីការបង្កើត និងការលុបការចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវធ្វើឡើងទាំងនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី និងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ។

ក្នុងករណីដែលមានការសន្យាពិសេស នៃសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវចុះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីថា មានភ្ជាប់ការសន្យាពិសេស រីឯនៅក្នុងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍វិញ ត្រូវចុះនូវចំណុចលំអិត នៃការសន្យាពិសេសនោះ ។

ចំពោះការផ្លាស់ប្តូរ ឬ ការកែតម្រូវសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬ/និង សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ។ ក៏ប៉ុន្តែបើមានការផ្លាស់ប្តូរ ឬ ការកែតម្រូវការសន្យាពិសេស ត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ។

ក្នុងករណីដែលមានការលុបចោលនូវការសន្យាពិសេស នៃសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវចុះទាំងនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី និងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ។

ចំពោះការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ និងការបង្កើតសិទ្ធិប្រាតិភោគលើសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ។

៣. ការចុះបញ្ជី អំពីការបង្កើត និងការលុបការចុះបញ្ជីផលុបភោគ ត្រូវធ្វើឡើងទាំងនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី និងសៀវភៅចុះបញ្ជីផលុបភោគ ។

ក្នុងករណី ដែលមានការសន្យាពិសេសនៃផលុបភោគ ត្រូវចុះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីថា មានភ្ជាប់ការសន្យាពិសេស រីឯនៅក្នុងសៀវភៅចុះបញ្ជីផលុបភោគវិញ ត្រូវចុះនូវចំណុចលំអិត នៃការសន្យាពិសេសនោះ ។

ចំពោះការផ្លាស់ប្តូរ ឬ ការកែតម្រូវផលុបភោគ ត្រូវចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬ/និងសៀវភៅចុះបញ្ជីផលុបភោគ ។ ក៏ប៉ុន្តែបើមានការផ្លាស់ប្តូរ ឬ ការកែតម្រូវការសន្យាពិសេស ត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជីផលុបភោគ ។

ក្នុងករណីដែលមានការលុបចោលនូវការសន្យាពិសេស នៃផលុបភោគ ត្រូវចុះទាំងនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី និងសៀវភៅចុះបញ្ជីផលុបភោគ ។

ចំពោះការផ្ទេរផលុបភោគ និងការបង្កើតសិទ្ធិប្រាតិភោគលើផលុបភោគ ត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជីផលុបភោគ ។

៤. ការចុះបញ្ជី អំពីការបង្កើត ការផ្លាស់ប្តូរ ការកែតម្រូវ និងការលុបការចុះបញ្ជី អំពីសេវភាព ត្រូវធ្វើឡើងនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

៥. ការចុះបញ្ជី អំពីការបង្កើត ការផ្ទេរ ការផ្លាស់ប្តូរ ការកែតម្រូវ និងការលុបការចុះបញ្ជីសិទ្ធិប្រាតិភោគត្រូវធ្វើឡើងនៅក្នុងសៀវភៅចុះបញ្ជីដែលពាក់ព័ន្ធ ។

៦. ការចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកសិទ្ធិអវិភាគ ត្រូវធ្វើឡើងនៅក្នុងសៀវភៅចុះបញ្ជីដែលពាក់ព័ន្ធ។

៧. ការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ ត្រូវធ្វើឡើងនៅក្នុងសៀវភៅចុះបញ្ជីដែលពាក់ព័ន្ធ ។

## កថាភាគទី ១
## របៀបចុះបញ្ជី អំពីកម្មសិទ្ធិ

### ប្រការ ៩០: របៀបចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ ដែលបានកំណត់នៅក្នុងប្រការ ២៨ (ពាក្យសុំចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ) គឺត្រូវចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ដូចខាងក្រោម ៖

ក- នៅក្នុងខ្ទង់ (column) ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ" ត្រូវសរសេរលេខរៀងចុះបញ្ជីពីមុខរួចសរសេរឈ្មោះរបស់បុគ្គលមានសិទ្ធិចុះបញ្ជី ជាទឹកខៀវ ឬ ខ្មៅ ។

ខ- នៅក្នុងខ្ទង់ (column) ត្រង់ " ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត" ត្រូវសរសេរ ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើតរបស់បុគ្គលមានសិទ្ធិចុះបញ្ជី ជាទឹកខៀវ ឬ ខ្មៅ ។

គ- នៅក្នុងខ្ទង់ (column) ត្រង់ "សាវតា" ត្រូវសរសេរឈ្មោះឪពុកម្តាយរបស់បុគ្គលមានសិទ្ធិចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ ។

ឃ- នៅក្នុងខ្ទង់ (column) ត្រង់ "លេខាចារឹកដោយសង្ខេប នៃលិខិតសញ្ញា ឬ សាលក្រមតុលាការ" ត្រូវសរសេរដូចខាងក្រោម ៖

(១) ករណីលក់ទិញ ៖

– ក្នុងករណីផ្ទេរកម្មសិទ្ធិទាំងមូលឲ្យទៅបុគ្គលតែម្នាក់ "ឈ្មោះ............ លក់ឲ្យឈ្មោះ............ សំបុត្រចុះថ្ងៃ...............លរ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

– ក្នុងករណីផ្ទេរកម្មសិទ្ធិទាំងមូលឲ្យទៅបុគ្គលលើសពីម្នាក់ "ឈ្មោះ.......... លក់ឲ្យឈ្មោះ........... ចំណែក............. ឈ្មោះ...............ចំណែក...............សំបុត្រចុះថ្ងៃ...............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

– ក្នុងករណីផ្ទេរកម្មសិទ្ធិមួយផ្នែកឲ្យទៅបុគ្គលតែម្នាក់ "ឈ្មោះ.................... លក់មួយផ្នែកឲ្យ ឈ្មោះ................ចំណែក..........សំបុត្រចុះថ្ងៃ...............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

– ក្នុងករណីផ្ទេរកម្មសិទ្ធិមួយផ្នែកឲ្យទៅបុគ្គលលើសពីម្នាក់ "ឈ្មោះ............ លក់មួយផ្នែកឲ្យ ឈ្មោះ................ចំណែក..........ឈ្មោះ................ចំណែក.......... សំបុត្រចុះថ្ងៃ...............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

(២) ករណីប្រទានកម្ម ៖

– ក្នុងករណីផ្ទេរកម្មសិទ្ធិទាំងមូលឲ្យទៅបុគ្គលតែម្នាក់ "ឈ្មោះ............ ឲ្យទៅឈ្មោះ............ សំបុត្រចុះថ្ងៃ............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

– ក្នុងករណីផ្ទេរកម្មសិទ្ធិទាំងមូលឲ្យទៅបុគ្គលលើសពីម្នាក់ "ឈ្មោះ......... ឲ្យទៅឈ្មោះ......... ចំណែក.............ឈ្មោះ.................ចំណែក.............សំបុត្រចុះថ្ងៃ..............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

– ក្នុងករណីផ្ទេរកម្មសិទ្ធិមួយផ្នែកឲ្យទៅបុគ្គលតែម្នាក់ "ឈ្មោះ................ ឲ្យមួយផ្នែកទៅ ឈ្មោះ......................ចំណែក...............សំបុត្រចុះថ្ងៃ............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

– ក្នុងករណីផ្ទេរកម្មសិទ្ធិមួយផ្នែកឲ្យទៅបុគ្គលលើសពីម្នាក់ "ឈ្មោះ.............. ឲ្យមួយផ្នែកទៅ ឈ្មោះ..............ចំណែក...............ឈ្មោះ...............ចំណែក...............សំបុត្រចុះថ្ងៃ............ល.រ AC..... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

(៣) ករណីដូរ ៖

ចំពោះរបៀបចុះបញ្ជីបន្ថែម នៃដីបម្រើនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ៖

ក- ការផ្លាស់ប្តូរអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ/និង ការសន្យាពិសេស៖ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ រួចចុះអំឡុងពេលថ្មី គោលបំណងថ្មី ទំហំថ្មី តម្លៃថ្នូរថ្មី ពេលវេលានៃការបង់តម្លៃថ្នូរថ្មី ឬ/និង ការសន្យាពិសេសថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ-លេខ...... ការផ្លាស់ប្តូរអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ/និង ការសន្យាពិសេស........ តាម.............. ចុះថ្ងៃ.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "អំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ/និង ការសន្យាពិសេស" ដែលខុសនោះ រួចត្រូវសរសេរលេខយោងក្នុងវង់ក្រចក ហើយត្រូវសរសេរអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ/និង ការសន្យាពិសេស ដែលត្រឹមត្រូវនៅក្បែរនោះ ដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ-លេខ........................ យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) អំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ/និង ការសន្យាពិសេស.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោងក្នុងវង់ក្រចក រួចត្រូវសរសេរអំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ

ឬ/និង ការសន្យាពិសេស ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ-លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថា: (លេខយោង) អំឡុងពេល គោលបំណង ទំហំ តម្លៃថ្នូរ ពេលវេលានៃការបង់តម្លៃថ្នូរ ឬ/និង ការសន្យាពិសេស..........."ជាទឹកក្រហម រួចបោះត្រាលេខាចារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ចំពោះរបៀបចុះបញ្ជីចម្បង នៃដីប្រើនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី៖

ក- ការផ្លាស់ប្តូរគោលបំណង ឬ/និង ទំហំ៖ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ រួចចុះគោលបំណងថ្មី ឬ/និង ទំហំថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ.........ផ្លាស់ប្តូរគោលបំណង ឬ/និង ទំហំ តាម............. ចុះថ្ងៃ............" ជាទឹកក្រហម រួចបោះត្រាលេខាចារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "គោលបំណង ឬ/និង ទំហំ" ដែលខុសនោះ រួចត្រូវសរសេរលេខយោងក្នុងវង់ក្រចក ហើយត្រូវសរសេរគោលបំណង ឬ/និង ទំហំដែលត្រឹមត្រូវនៅក្បែរនោះ ដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថា: (លេខយោង) គោលបំណង ឬ/និង ទំហំ .........." ជាទឹកក្រហម រួចបោះត្រាលេខាចារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោង ក្នុងវង់ក្រចក រួចត្រូវសរសេរគោលបំណង ឬ/និង ទំហំដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ.........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថា: (លេខយោង) គោលបំណង ឬ/និង ទំហំ ............"ជាទឹកក្រហម រួចបោះត្រាលេខាចារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ចំពោះរបៀបចុះបញ្ជីបន្ថែមនៃដីប្រើនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ៖

ក- ការផ្លាស់ប្តូរគោលបំណង ឬ/និង ទំហំ៖ មន្ត្រីចុះបញ្ជី ត្រូវចុះលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី៣ នៃប្រការ ៨៣ រួចត្រូវចុះគោលបំណងថ្មី ឬ/និង ទំហំថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ-លេខ...... ការផ្លាស់ប្តូរគោលបំណង ឬ/និង ទំហំ........ តាម............. ចុះថ្ងៃ..........." ជាទឹកក្រហម រួចបោះត្រាលេខាចារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "គោលបំណង ឬ/និង ទំហំ" ដែលខុសនោះ រួចសរសេរលេខយោងក្នុងវង់ក្រចក ហើយសរសេរគោលបំណង ឬ/និង ទំហំ ដែលត្រឹមត្រូវនៅក្បែរនោះ ដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ-លេខ..... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) គោលបំណង ឬ/និង ទំហំ ......" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោងក្នុងវង់ក្រចក រួចត្រូវសរសេរគោលបំណង ឬ/និង ទំហំដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ-លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) គោលបំណង ឬ/និង ទំហំ.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

## ប្រការ ១០៧ : របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសេវភាព

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសេវភាព ដែលបានកំណត់នៅក្នុងប្រការ ៤៧ (ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសេវភាព) គឺត្រូវចុះបញ្ជីដូចខាងក្រោម៖

- នៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីបម្រើ ត្រូវឆូតដោយទឹកក្រហមលើចំណុចដែលបានចុះនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា "លេខ.........លុបការចុះបញ្ជី អំពីសេវភាព ដោយមូលហេតុ ការផុតអំឡុងពេល ការលុបចោលកិច្ចសន្យា ឬ ការព្រមព្រៀងគ្នារំលាយកិច្ចសន្យាចុះថ្ងៃ..........." ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

- នៅក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃដីប្រើ ត្រូវឆូតដោយទឹកក្រហមនៅលើចំណុចដែលបានចុះនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ហើយត្រូវសរសេរនៅក្នុងខ្ទង់(column) ត្រង់ "សេចក្តីផ្សេងៗ" ថា "លេខ...... លុបការចុះបញ្ជីសេវភាព ដោយមូលហេតុ ការផុតអំឡុងពេល ការលុបចោលកិច្ចសន្យា ឬការព្រមព្រៀងគ្នារំលាយកិច្ចសន្យាចុះថ្ងៃ............." ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

## កថាភាគទី ៥
## របៀបចុះបញ្ជី អំពីឯកសិទ្ធិ

## ប្រការ ១០៨ : របៀបចុះបញ្ជី អំពីឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីឯកសិទ្ធិ ដែលបានកំណត់នៅក្នុងប្រការ ៤៨ (ពាក្យសុំចុះបញ្ជី អំពីឯកសិទ្ធិសម្រាប់ការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬសៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ............បង្កើតឯកសិទ្ធិឲ្យឈ្មោះ...... កូនបំណុល............ចំនួនទឹកប្រាក់សិទ្ធិលើបំណុល.........ការប្រាក់...............% សំណងការខូចខាត...........% ដោយផ្អែកលើការរក្សាទុកនូវអចលនវត្ថុ ឬ ការងារលើអចលនវត្ថុ ឬ ការលក់អចលនវត្ថុ............ ចុះថ្ងៃ........." ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

## ប្រការ ១០៩ : របៀបចុះបញ្ជី អំពីការផ្ទេរឯកសិទ្ធិ

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្ទេរឯកសិទ្ធិ ដែលបានកំណត់នៅក្នុងប្រការ ៤៩ (ពាក្យសុំចុះបញ្ជី អំពីការផ្ទេរឯកសិទ្ធិ) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬសៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ-លេខ..........ឈ្មោះ............. ផ្ទេរឯកសិទ្ធិ ឬ ផ្ទេរចំណែកឯកសិទ្ធិ ឬផ្ទេរឯកសិទ្ធិមួយផ្នែកលេខ......... ចំនួន.........ចំណែក.............ទៅឲ្យឈ្មោះ.................. តាម.............. ចុះថ្ងៃ............." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

## ប្រការ ១១០ : របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីឯកសិទ្ធិ

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីឯកសិទ្ធិ ដែលបានកំណត់នៅក្នុងប្រការ ៥០ (ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីឯកសិទ្ធិ) ត្រូវឆូតដោយទឹកក្រហមលើចំណុចដែលបានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬសៀវភៅចុះបញ្ជីផលុបភោគ) នៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ឬ/និង ក្នុងខ្ទង់ (Column) ត្រង់ "សេចក្ដីផ្សេងៗ" ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា "លេខ............ លុបការចុះបញ្ជី អំពីឯកសិទ្ធិលេខ............ ដោយមូលហេតុ ការសង ឬ ការបោះបង់ឯកសិទ្ធិ ចុះថ្ងៃ.......... " ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

# កថាភាគទី ៦
# របៀបចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ

## ប្រការ ១១១ : របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ ដែលបានកំណត់នៅក្នុងប្រការ ៥១ (ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ....... បញ្ចាំឲ្យឈ្មោះ............. កូនបំណុល............ អំឡុងពេល............. ប្រាក់ដើម........... ប្រាក់ធានាសង............ លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា...............ការសន្យាពិសេស............. តាមកិច្ចសន្យា...........ចុះថ្ងៃ............និងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃ........តារាងប្រាតិភោគរួមលេខ........." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

## ប្រការ ១១២ : របៀបចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ ដែលបានកំណត់នៅក្នុងប្រការ ៥២ (ពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬសៀវភៅចុះបញ្ជីផលុបភោគ)ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ " លេខ-លេខ...... ផ្ទេរសិទ្ធិលើការបញ្ចាំ ឬ ផ្ទេរចំណែកសិទ្ធិលើការបញ្ចាំ ឬផ្ទេរ

សិទ្ធិលើការបញ្ចាំមួយផ្នែក លេខ......... ចំនួន.......... ចំណែក.......... ឲ្យឈ្មោះ............ តាម........ ចុះថ្ងៃ........" ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាធារីក និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

**ប្រការ ១១៣ : របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត ដែលបានកំណត់នៅក្នុងប្រការ ៥៣ (ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ-លេខ..... បង្កើតការបញ្ចាំបន្តលើការបញ្ចាំលេខ......... ឲ្យឈ្មោះ.............. កូនបំណុល................ អំឡុងពេល............. ប្រាក់ដើម............... ប្រាក់ធានាសង.......... លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា.............. ការសន្យាពិសេស.................. តាមកិច្ចសន្យា............... ចុះថ្ងៃ..............និងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំបន្ត ចុះថ្ងៃ............." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាធារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

**ប្រការ ១១៤ : របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវសិទ្ធិលើការបញ្ចាំ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវសិទ្ធិលើការបញ្ចាំ ដែលបានកំណត់នៅក្នុងប្រការ ៥៤ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវសិទ្ធិលើការបញ្ចាំ) គឺ ត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ដូចខាងក្រោម៖

ចំពោះរបៀបចុះបញ្ជីចម្បង ៖

ក– ការផ្លាស់ប្តូរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស៖ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី១ នៃប្រការ ៨៣ រួចចុះចំនួនប្រាក់ដើមថ្មី សំណងការខូចខាតថ្មី អំឡុងពេលថ្មី លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានាថ្មី ឬ/និង ការសន្យាពិសេសថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ.........ផ្លាស់ប្តូរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស........... តាម.............. ចុះថ្ងៃ............" ជាទឹកក្រហម រួចបោះត្រាលេខាធារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ– ករណីកែតម្រូវដោយសរសេរខុស: មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "ចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស" ដែលខុសនោះ រួចត្រូវសរសេរលេខយោងក្នុងវង់ក្រចក ហើយត្រូវសរសេរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេសដែលត្រឹមត្រូវនៅក្បែរនោះដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថា: (លេខយោង) ចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស.........." ជាទឹកក្រហម រួចបោះត្រាលេខាធារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោង ក្នុងវង់ក្រចក រួចត្រូវសរសេរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងដោយអនុលោមតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស............" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ចំពោះរបៀបចុះបញ្ជីបន្ថែម ៖

ក- ការផ្លាស់ប្តូរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស៖ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី៣ នៃប្រការ ៨៣ រួចចុះចំនួនប្រាក់ដើមថ្មី សំណងការខូចខាតថ្មី អំឡុងពេលថ្មី លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានាថ្មី ឬ/និង ការសន្យាពិសេសថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ-លេខ......... ការផ្លាស់ប្តូរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស........ តាម............. ចុះថ្ងៃ..........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "ចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស" ដែលខុសនោះ រួចសរសេរលេខយោងក្នុងវង់ក្រចក ហើយសរសេរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស ដែលត្រឹមត្រូវនៅក្បែរនោះ ដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខាដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ-លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោងក្នុងវង់ក្រចក រួចត្រូវសរសេរចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះជាបញ្ជីនោះ ទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ-លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ប្រាក់ធានាសង អំឡុងពេល លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ/និង ការសន្យាពិសេស..........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

**ប្រការ ១១៥ : របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ ដែលបានកំណត់នៅក្នុងប្រការ ៥៥ (ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ) គឺត្រូវឆូត ដោយទឹកក្រហមលើចំណុចដែលបានចុះនៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ឬ/និង ក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា "លេខ ...........លុបការចុះបញ្ជី អំពីការបញ្ចាំលេខ............. ដោយមូលហេតុ ការសង ឬ ការបោះបង់សិទ្ធិ ឬ ការព្រមព្រៀងគ្នារំលាយកិច្ចសន្យាចុះថ្ងៃ.........." ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

## កថាភាគទី ៧
## របៀបចុះបញ្ជី អំពីហ៊ីប៉ូតែក

**ប្រការ ១១៦ : របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៥៦ (ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ.......... បង្កើតហ៊ីប៉ូតែកឲ្យឈ្មោះ................. កូនបំណុល............. ប្រាក់ដើម........... ការប្រាក់........% សំណងការខូចខាត.........% លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា.............. តាមកិច្ចសន្យា........... ចុះថ្ងៃ........ និង កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃ......... តារាងប្រាតិភោគរួមលេខ........." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម ។

**ប្រការ ១១៧ : របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត ដែលបានកំណត់នៅក្នុងប្រការ ៥៧ (ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ-លេខ.......... បង្កើតហ៊ីប៉ូតែកបន្តលើហ៊ីប៉ូតែកលេខ......... ឲ្យឈ្មោះ............ កូនបំណុល......ប្រាក់ដើម............ការប្រាក់.........% សំណងការខូចខាត...........% លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា.............. តាមកិច្ចសន្យា............. ចុះថ្ងៃ..............និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកបន្តចុះថ្ងៃទី.........." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម។

**ប្រការ ១១៨ : របៀបចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៥៨ (ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក) គឺត្រូវចុះក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ-លេខ.......ផ្ទេរហ៊ីប៉ូតែក ឬ ផ្ទេរចំណែកហ៊ីប៉ូតែក ឬ ផ្ទេរហ៊ីប៉ូតែកមួយផ្នែក លេខ........ ចំនួន.........

ចំណែក........ឲ្យឈ្មោះ........ តាម......... ចុះថ្ងៃ.................." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

**ប្រការ១១៩ : របៀបចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម ដែលបានកំណត់នៅក្នុងប្រការ ៥៩ (ពាក្យសុំចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ-លេខ.....ធ្វើឧបាទេសកម្មហ៊ីប៉ូតែករួមលើអចលនវត្ថុ......... ទៅឈ្មោះ.......... ប្រាក់ដើម.......... ការប្រាក់..........% សំណងការខូចខាត.........% ប្រាក់ថ្លៃលក់............ ប្រាក់សង......... តាមឧបាទេសកម្មដោយផ្អែកលើមាត្រា ៨៥៨ នៃក្រមរដ្ឋប្បវេណី ចុះថ្ងៃ........." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

**ប្រការ ១២០ : របៀបចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៦០ (ពាក្យសុំចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬ ការបោះបង់ហ៊ីប៉ូតែក) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ-លេខ..... ធ្វើអនុប្បទាន ឬ បោះបង់ហ៊ីប៉ូតែកលេខ........ឲ្យឈ្មោះ......... កូនបំណុល..........ប្រាក់ដើម............ការប្រាក់........% សំណងការខូចខាត.........% លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុល............ តាមកិច្ចសន្យាអនុប្បទាន ឬ បោះបង់ហ៊ីប៉ូតែក ចុះថ្ងៃ..............." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

**ប្រការ ១២១ : របៀបចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៦១ (ពាក្យសុំចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬ ការបោះបង់លំដាប់ហ៊ីប៉ូតែក) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ)ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ-លេខ... អនុប្បទាន ឬ បោះបង់លំដាប់ហ៊ីប៉ូតែកលេខ...... ឲ្យហ៊ីប៉ូតែកលេខ........... តាមកិច្ចសន្យាអនុប្បទាន ឬ បោះបង់លំដាប់ហ៊ីប៉ូតែក ចុះថ្ងៃ............." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

**ប្រការ ១២២ : របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៦២ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ-លេខ........ លេខ-លេខ......... ប្តូរលំដាប់ហ៊ីប៉ូតែកលេខ....... ទៅលេខ......ពីលំដាប់ហ៊ីប៉ូតែកលេខ.......មកលេខ......... តាមកិច្ចសន្យាផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក ចុះថ្ងៃ.........."

ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

**ប្រការ ១២៣ : របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវហ៊ីប៉ូតែក**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៦៣ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវហ៊ីប៉ូតែក) គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ដូចខាងក្រោម ៖

ចំពោះរបៀបចុះបញ្ជីចម្បង ៖

ក- ការផ្លាស់ប្តូរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ៖ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី១ នៃប្រការ ៨៣ រួចចុះចំនួនប្រាក់ដើមថ្មី ការប្រាក់ថ្មី សំណងការខូចខាតថ្មី ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានាថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ................ការផ្លាស់ប្តូរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា តាម.............. ចុះថ្ងៃ............" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "ចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា" ដែលខុសនោះ រួចត្រូវសរសេរលេខយោងក្នុងវង់ក្រចក ហើយត្រូវសរសេរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលត្រឹមត្រូវនៅក្បែរនោះដោយទឹកក្រហម និងត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោង ក្នុងវង់ក្រចក រួចត្រូវសរសេរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា......." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ចំពោះរបៀបចុះបញ្ជីបន្ថែម

ក- ការផ្លាស់ប្តូរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ៖ មន្ត្រីចុះបញ្ជី ត្រូវចុះលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ រួចចុះចំនួនប្រាក់ដើមថ្មី ការប្រាក់ថ្មី សំណងការខូចខាតថ្មី ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើ

បំណុលដែលត្រូវបានធានាថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ-លេខ......... ការផ្លាស់ប្តូរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានាតាម............. ចុះថ្ងៃ..........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ– ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "ចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា" ដែលខុសនោះ រួចសរសេរលេខយោងក្នុងវង់ក្រចក ហើយ សរសេរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលត្រឹមត្រូវនៅក្បែរនោះ ដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ-លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ– ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោងក្នុងវង់ក្រចក រួចត្រូវសរសេរចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ-លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ចំនួនប្រាក់ដើម ការប្រាក់ សំណងការខូចខាត ឬ/និង លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

### ប្រការ ១២៤ : របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក ដែលបានកំណត់នៅក្នុងប្រការ ៦៤ (ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក) គឺត្រូវឆូតដោយទឹកក្រហមលើចំណុចដែលបានចុះនៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ឬ/និង ក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា "លេខ...........លុបការចុះបញ្ជីអំពីហ៊ីប៉ូតែកលេខ......... ដោយមូលហេតុ ការសង ឬ ការបោះបង់សិទ្ធិ ឬ ការព្រមព្រៀងគ្នារំលាយកិច្ចសន្យាចុះថ្ងៃ......... " ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

## កថាភាគទី ៨
## របៀបចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

### ប្រការ ១២៥: របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានកំណត់នៅក្នុងប្រការ ៦៥ (ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) គឺត្រូវ

ចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ............ បង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឲ្យឈ្មោះ..........កូនបំណុល...........ប្រាក់អតិបរមា................ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា...........កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ..........ការសន្យាពិសេស...........តាមកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ចុះថ្ងៃ........" ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

### ប្រការ ១២៦ : របៀបចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានកំណត់នៅក្នុងប្រការ ៦៦ (ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) គឺត្រូវចុះក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ថា: "លេខ-លេខ.......ផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ............ ឲ្យឈ្មោះ................ តាម.......... ចុះថ្ងៃ.................." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

### ប្រការ ១២៧ : របៀបចុះបញ្ជី អំពីការបែងចែក និង អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការបែងចែក និង អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានកំណត់នៅក្នុងប្រការ ៦៧ (ពាក្យសុំចុះបញ្ជី អំពីការបែងចែក និង អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) គឺត្រូវចុះក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា:

"លេខ-អក្ខរសញ្ញា....បែងចែក និង អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតលេខ......... ឲ្យឈ្មោះ.....................ប្រាក់អតិបរមា........ កូនបំណុល........... ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា........ កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ.............ការសន្យាពិសេស............កិច្ចសន្យាបែងចែក និង អនុប្បទាន ចុះថ្ងៃ..........." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកក្រហម។

"លេខ-អក្ខរសញ្ញា-លេខ......ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតលេខ............ ប្រាក់អតិបរមា ក្រោយពេលបែងចែក និង អនុប្បទាន.................... កិច្ចសន្យាបែងចែក និង អនុប្បទាន ចុះថ្ងៃ................." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

### ប្រការ ១២៨: របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានកំណត់នៅក្នុងប្រការ ៦៨ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) ប្រការ ៦៩ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរទំហំ នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) ប្រការ ៧០ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) និង ការចុះបញ្ជី អំពីការផ្លាស់ប្តូរកូនបំណុល គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ

សៀវភៅចុះបញ្ជីផលុបភោគ) នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ រួចចុះចំនួនទឹកប្រាក់អតិបរមាថ្មី ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាថ្មី កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរថ្មី កូនបំណុលថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

លេខ-លេខ......ការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមា ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ.... កូនបំណុល....... តាម.........ចុះថ្ងៃ........" ជាទឹកក្រហម រួចបោះត្រាលេខាចារីកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

## ប្រការ ១២៩: របៀបចុះបញ្ជី អំពីការព្រមព្រៀងគ្នារបស់សន្តតិជននៃម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត និង/ឬ កូនបំណុល

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការព្រមព្រៀងគ្នារបស់សន្តតិជននៃម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) នៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ-លេខ........កូនបំណុលឈ្មោះ......... ឬ ម្ចាស់បំណុលឈ្មោះ......តាមការព្រមព្រៀង ចុះថ្ងៃ..." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

## ប្រការ ១៣០: របៀបចុះបញ្ជី អំពីកាលបរិច្ឆេទ ដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត គឺត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) នៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថាៈ "លេខ-លេខ........ហ៊ីប៉ូតែកធានាបំណុលអណ្តែតលេខ............ ប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៅថ្ងៃ........... សំបុត្រចុះថ្ងៃ............" ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារីក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។

## ប្រការ ១៣១: របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលបានកំណត់នៅក្នុងប្រការ ៧១ (ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) គឺត្រូវឆូតដោយទឹកក្រហមលើចំណុចដែលបានចុះនៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ឬ/និងក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា "លេខ................លុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ........... ដោយមូលហេតុ ការសង ឬ ការបោះបង់សិទ្ធិ ឬ ការព្រមព្រៀងគ្នាលែងយកកិច្ចសន្យា ចុះថ្ងៃ.........." ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារីក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

## កថាភាគទី ៩
## របៀបចុះបញ្ជី អំពីសិទ្ធិបន្ទាប់បន្សំមួយចំនួនដែលពាក់ព័ន្ធនៅនឹងសិទ្ធិប្រត្យក្ស

**ប្រការ ១៣២: របៀបចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ ដែលបានកំណត់នៅក្នុងប្រការ ៧២ (ពាក្យសុំចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ) គឺត្រូវចុះក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "លេខាចារឹកដោយសង្ខេប នៃលិខិតសញ្ញា ឬ សាលក្រមតុលាការ" ថា: "លេខ-លេខ........ ឈ្មោះ......... លក់ឲ្យឈ្មោះ.......... ក្នុងតម្លៃ........... សោហ៊ុយធ្វើកិច្ចសន្យា........... អំឡុងពេលលោះ........... តាមការសន្យាពិសេសនៃការលោះ ចុះថ្ងៃ............" ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

**ប្រការ ១៣៣: របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះ គឺត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "លេខាចារឹកដោយសង្ខេប នៃលិខិតសញ្ញា ឬ សាលក្រមតុលាការ" ថា: "លេខ.........លុបការចុះបញ្ជី អំពីការសន្យាពិសេសនៃការលោះលេខ-លេខ......ដោយមូលហេតុការផុតអំឡុងពេល ឬ ការអនុវត្តសិទ្ធិលោះ ឬ ព្យាកុលភាព ចុះថ្ងៃ......." ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

**ប្រការ ១៣៤: របៀបចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ដែលបានកំណត់នៅក្នុងប្រការ ៧៣ (ពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ) គឺត្រូវចុះក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា: "លេខ-លេខ......... ហាមបែងចែកអចលនវត្ថុអវិភាគ អំឡុងពេល តាមការសន្យាពិសេស ចុះថ្ងៃ......" ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

**ប្រការ ១៣៥: របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬការកែតម្រូវ អំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ដែលបានកំណត់នៅក្នុងប្រការ ៧៤ (ពាក្យសុំចុះបញ្ជី អំពីផ្លាស់ប្តូរអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ) ប្រការ ៧៥ (ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវអំឡុងពេលហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ) គឺត្រូវចុះក្នុងសៀវភៅចុះបញ្ជី (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ដូចខាងក្រោម ៖

ចំពោះរបៀបចុះបញ្ជីចម្បង

ក- ការផ្លាស់ប្តូរអំឡុងពេល៖ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី១ នៃប្រការ ៨៣ រួចចុះអំឡុងពេលថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ....................ផ្លាស់ប្តូរអំឡុងពេល............តាម.............ចុះថ្ងៃ............" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "អំឡុងពេល" ដែលខុសនោះ រួចត្រូវសរសេរលេខយោងក្នុងវង់ក្រចក ហើយត្រូវសរសេរអំឡុងពេល ដែលត្រឹមត្រូវនៅក្បែរនោះដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមទៅតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) អំឡុងពេល.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោង ក្នុងវង់ក្រចក រួចត្រូវសរសេរអំឡុងពេល ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀង ដោយអនុលោមតាមកថាខណ្ឌទី ១ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) អំឡុងពេល............"ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ចំពោះរបៀបចុះបញ្ជីបន្ថែម

ក- ការផ្លាស់ប្តូរអំឡុងពេលៈ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី៣ នៃប្រការ ៨៣ រួចចុះអំឡុងពេលថ្មី នៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ-លេខ....................ផ្លាស់ប្តូរអំឡុងពេល............តាម.............ចុះថ្ងៃ............" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "អំឡុងពេល" ដែលខុសនោះ រួចសរសេរលេខយោងក្នុងវង់ក្រចក ហើយសរសេរអំឡុងពេល ដែលត្រឹមត្រូវនៅក្បែរនោះ ដោយទឹកក្រហម និង ត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ-លេខ....... យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) អំឡុងពេល.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្ត្រីចុះបញ្ជីត្រូវសរសេរលេខយោងក្នុងវង់ក្រចក រួចត្រូវសរសេរអំឡុងពេល ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ-លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) អំឡុងពេល..........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

**ប្រការ ១៣៦: របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគដែលបានកំណត់នៅក្នុងប្រការ ៧៦ (ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ) គឺត្រូវឆូតដោយទឹកក្រហមលើចំណុចដែលបានចុះនៅក្នុងខ្ទង់ (Column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ឬ/និងក្នុងខ្ទង់ (Column) ត្រង់ "សេចក្តីផ្សេងៗ" ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "បន្ទុកលើអចលនវត្ថុ" ថា "លេខ................លុបការចុះបញ្ជី អំពីការហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ដោយមូលហេតុ ការផុតអំឡុងពេល ឬការព្រមព្រៀងគ្នារំលាយ......... " ជាទឹកខៀវ ឬ ខ្មៅ រួចបោះត្រាលេខាចារឹក និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម ។

## កថាភាគទី ១០
## របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ

**ប្រការ ១៣៧: របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ**

នៅពេលរដ្ឋបាលសុរិយោដី បានទទួលពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬ កែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ ដែលបានកំណត់នៅក្នុងប្រការ ៧៧ (ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ) ប្រការ ៧៨ (ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ) គឺត្រូវចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីពាក់ព័ន្ធ (សៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ) ដូចខាងក្រោម ៖

ក- ការផ្លាស់ប្តូរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិៈ មន្ត្រីចុះបញ្ជី ត្រូវចុះលេខរៀង បន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី៣ នៃប្រការ ៨៣ រួចចុះឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយថ្មី នៅក្នុងខ្ទង់ "សេចក្តីផ្សេងៗ" ដូចខាងក្រោម ៖

"លេខ-លេខ......ប្តូរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយរបស់ម្ចាស់សិទ្ធិ......... ទៅជា..............តាម........ចុះថ្ងៃទី....." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

ខ- ករណីកែតម្រូវដោយសរសេរខុសៈ មន្ត្រីចុះបញ្ជីត្រូវគូសបន្ទាត់ពីក្រោម "ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ" ដែលខុសនោះ រួចត្រូវសរសេរលេខយោងក្នុងវង់ក្រចក ហើយត្រូវ សរសេរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ ដែលត្រឹមត្រូវនៅក្បែរនោះដោយទឹកក្រហម និងត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមទៅតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម ៖

"លេខ-លេខ.....យល់ព្រមលុប និង កែតាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ" ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

គ- ករណីកែតម្រូវដោយការខកខានមិនបានចុះអស់សេចក្តីក្នុងសៀវភៅចុះបញ្ជីៈ មន្រ្តីចុះបញ្ជីត្រូវសរសេរលេខយោង ក្នុងវង់ក្រចក រួចត្រូវសរសេរឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ ដែលខកខានមិនបានចុះបញ្ជី នៅក្បែរកន្លែងខកខានមិនបានចុះបញ្ជីនោះ ជាទឹកក្រហម ហើយត្រូវសរសេរនៅក្នុងខ្ទង់ (column) ត្រង់ "សេចក្តីផ្សេងៗ" នូវលេខរៀងបន្តដោយលេខលំដាប់សាខា ដោយអនុលោមតាមកថាខណ្ឌទី ៣ នៃប្រការ ៨៣ ដូចខាងក្រោម៖

"លេខ–លេខ........យល់ព្រមសរសេរថែម តាមទឹកក្រហម ខ្ញុំថាៈ (លេខយោង) ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ.........." ជាទឹកក្រហម រួចបោះត្រាលេខាចារឹកជាទឹកខៀវ និង ចុះកាលបរិច្ឆេទ នៃការចុះបញ្ជីជាទឹកខៀវ ឬ ខ្មៅ។

# ជំពូកទី ៦
# នីតិវិធីនៃការសុំមើល និងការសុំចេញលិខិតបញ្ជាក់អំពីព័ត៌មានដែលបានចុះបញ្ជី

## ប្រការ ១៣៨ : របៀបដាក់ពាក្យសុំមើល និងសុំឲ្យបញ្ជាក់

១- ពាក្យសុំទាមទារមើល និងសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

២- ពាក្យសុំទាមទារមើល និងសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ ឬ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល។

៣- ពាក្យសុំទាមទារមើល និងសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

- គោលបំណងនៃពាក្យសុំ ការសុំទាមទារមើល ឬ ការសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំជានីតិបុគ្គល
- ឈ្មោះសៀវភៅចុះបញ្ជី
- អត្តសញ្ញាណអចលនវត្ថុ ឬ/និង សិទ្ធិ
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមមេដៃ ។

៤- អ្នកដាក់ពាក្យសុំទាមទារមើល និងសុំឲ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ១៣៩ : ការអនុញ្ញាតឲ្យមើល និងការចេញលិខិតបញ្ជាក់

១- នៅពេលបានទទួលពាក្យសុំទាមទារមើល មន្រ្តីចុះបញ្ជីត្រូវអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំ មើលក្នុងសៀវភៅចុះបញ្ជី នៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុ តាំងនៅ ឬ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។

២- ក្រោយពីបានទទួលពាក្យសុំទាមទារមើល មន្រ្តីចុះបញ្ជី ត្រូវអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំទាមទារមើលនោះ មើលសៀវភៅចុះបញ្ជី ដោយពុំមានការយឺតយ៉ាវ តែយ៉ាងយូរបំផុតមិនឲ្យលើសរយៈពេល ៣ថ្ងៃ ។

៣- នៅពេលបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លង ឬ ចម្លងចេញពីសៀវភៅចុះបញ្ជីនូវខ្លឹមសារតាមការស្នើសុំ ដោយសរសេរលើលិខិតថតចម្លង ឬ ឯកសារចម្លងនោះថា ៖

- បានថតចម្លង ឬ បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
- ថ្ងៃទី...... ខែ...... ឆ្នាំ.........
- ហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និងហត្ថលេខា និងឈ្មោះរបស់ប្រធានរដ្ឋបាលសុរិយោដី និងត្រារបស់រដ្ឋបាលសុរិយោដី ។

៤- ក្រោយពីបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបញ្ជាក់ឲ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ តែយ៉ាងយូរបំផុតមិនឲ្យលើសរយៈពេល ៣ថ្ងៃ ។

## ជំពូកទី ៧
## លិខិតបញ្ជាក់ការចុះបញ្ជីសិទ្ធិប្រាតិភោគ

### ប្រការ ១៤០ : លិខិតបញ្ជាក់ការចុះបញ្ជីសិទ្ធិប្រាតិភោគ

១- នៅពេលបានចុះបញ្ជី អំពីសិទ្ធិប្រាតិភោគរួចហើយ រដ្ឋបាលសុរិយោដីត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីសិទ្ធិប្រាតិភោគនោះ ឲ្យទៅម្ចាស់សិទ្ធិប្រាតិភោគ ។

២- ចំពោះការចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីសិទ្ធិប្រាតិភោគ រដ្ឋបាលសុរិយោដីត្រូវថតចម្លងប័ណ្ណនៃអចលនវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ដោយសរសេរថា "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" រួចចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ព្រមទាំងបោះត្រាលើប័ណ្ណថតចម្លងនោះ ។

៣- នៅពេលមន្ត្រីចុះបញ្ជីបានបញ្ចប់ការចុះបញ្ជីរួច រដ្ឋបាលសុរិយោដីត្រូវប្រគល់ "វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ" ឬ "ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ" ឬ "ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី" ឬ "វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍" ឬ "វិញ្ញាបនបត្រសម្គាល់ផលុបភោគ" ជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ឲ្យទៅម្ចាស់ប័ណ្ណវិញ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

### ប្រការ ១៤១ : កាលបរិច្ឆេទ នៃការអនុវត្ត

១. ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែ បានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

២. ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ ក៏បញ្ញត្តិចាប់ពីប្រការ ២ ដល់ ប្រការ ១១ ប្រការ ១៣ ប្រការ ១៤ ប្រការ ២០ ប្រការ ២១ បញ្ញត្តិចាប់ពីប្រការ ២៣ ដល់ ប្រការ ២៧ បញ្ញត្តិចាប់ពីប្រការ ៥៦ ដល់ប្រការ ៧១ បញ្ញត្តិចាប់ពីប្រការ ៧៩ ដល់ ប្រការ ៨៥ ប្រការ ៨៨ ប្រការ ៨៩ កថាខណ្ឌទី ៥ បញ្ញត្តិចាប់ពីប្រការ ១១៦ ដល់ប្រការ ១៣១ និងបញ្ញត្តិនៃប្រការ ១៤០ នៃប្រកាសនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ។

**ប្រការ ១៤២ :  និរាករណ៍ នៃបទប្បញ្ញត្តិដែលផ្ទុយ**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានអានុភាពនៅពេលប្រកាសនេះ ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងប្រកាសនេះ ចាប់ពីថ្ងៃដែលប្រកាសនេះ ត្រូវបានអនុវត្ត ។

ជ.នាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**អ៊ឹម ឈុនលឹម**

ជ.នាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**អង្គ វង្សវឌ្ឍនា**

**<u>ចម្លងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- តុលាការគ្រប់ជាន់ថ្នាក់
- មហាអយ្យការអមតុលាការកំពូល
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមតុលាការរាជធានី ខេត្ត
- អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- សាលារាជធានី ខេត្ត
- មន្ទីរ ដនសស រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

បោះពុម្ពផ្សាយដោយ

ក្រសួងយុត្តិធម៌

ឧបត្ថម្ភដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន (JICA)

ហាមលក់